សារព័ត៌មាន ខ្មែរផុស ស.រ.អា

KhmerPost USA

E-mail: info@khmerpost.us / Website : khmerpost.us
Advertising: 978-656-8141/ Hotline news: 978-942-1641


## មាតិការឿង


Issue 164 0ct 31th-Nov 14.th, 2014

Free



១–ដំណើរពីអាមេរិកទៅអាស៊ី..........................០២
៣–ផលិតករភាពយន្ត"រឿងវាលពិឃាត"............០៥
៤–គិលានុបដ្ឋាកីរូបត្រូវឆ្លងជំងឺអេបូឡា..............០៦
៥–តើពលរដ្ឋជ្រើសយកនរណា?........................០៧
៦–គណបក្សសង្គ្រោះជាតិធ្វើសវនកម្មផ្ទៃ...............១០
៧–ភាពជាប់គាំងនៃវត្តត្រៃរតនារាមនៅតែបន្ត......១២
៨–ប្រជាពលរដ្ឋកោះរ៉ុង បោះបង់នេសាទ...............១៨
៩–ជាតិ សាសនា ព្រះមហាក្សត្រ........................១៩



New Office: Tel: (978) 677-7163 Fax: (978) 677-7092
45 Merrimack St. Suite 218A  Lowell, MA 01852


## វិចារណកថា

# បើសហគមន៍ខ្មែរ ចង់ខ្លាំងត្រូវតែទៅ បោះឆ្នោត



ពិន សំខុន

ខ្មែរនៅឡូវែលមានសំណាងជាងអ្នកនៅតំបន់ផ្សេងៗនៃសហរដ្ឋអាមេរិកទាំងអស់ដោយមានលទ្ធភាពគ្រប់គ្រាន់នឹងជ្រើសរើសដំណាងខ្លួនឯងសំរាប់ដំបន់ខ្លួនឯងបាន ពីព្រោះមានទំហំដល់ទៅ៣០ភាគរយនៃប្រជាពលរដ្ឋឡូវែលទាំងមូលបើប្រៀបធៀបទៅនឹងតំបន់ដែលមានប្រជាពលរដ្ឋខ្មែរ **តទៅទំព័រទី ០៩**

# នាំកូនរៀបការទៅចូលគាល់ព្រះមហាក្សត្រ



ព្រះមហាក្សត្រខ្មែរ ព្រះបាទបរមនាថនរោត្តម សីហមុនី បានរាជានុញ្ញាតិឱ្យគ្រួសារ ពិន សំខុន នឹង ស៊ីរីយ៉ា ស៊ីសូវត្តិ **តទៅទំព័រទី ០៣**


# ការិយាល័យច្បាប់ ហ្វ្រង់ស៊ីស្កូ ជេ.រ៉ូសា



Francisco J. Rosa, Esq.
មេធាវី ហ្វ្រង់ ស៊ីស្កូ ជេ.រ៉ូសា



Andrew ´Bunna´ Taing, Esq.
មេធាវី ប៊ុណ្ណា អែនឌ្រូ តាំង

Law Office of:
FRANCISCO J. ROSA
ATTORNEY AT LAW

SERVICES
- Auto Accidents/ Personal Injury
- Bankruptcy
- Immigration
- Consumer Protection
- Real Estate Closings/Disputes
- Divorces Child Custody

តំណាងក្តីដូចខាងក្រោម
- គ្រោះថ្នាក់រថយន្ត/ របួសរូបរាងកាយ
- ក្ស័យធន
- អន្តោប្រវេសន៍
- ការពារអតិថិជន
- ទំនាស់ផ្នែកអចលនវត្ថុ
- លែងលះ និងអាណាព្យាបាលកិច្ច

1550 Middlesex Street Lowell, MA 01851
Phone: **978-458-0934** | help@attorneyrosa.com
www.attorneyrosa.com



VMART LOWELL

ចាប់បើកហើយ !



ផ្សារម្ហូបអាស៊ី
មានម្ហូបច្រើនមុខដល់ទៅ ១២,០០០មុខ
សាច់ស្រស់ និងម្ហូបធ្វើហើយ ម្ហូបស្រស់ៗ
មកពីបសស្តូន, ញូយ៉ក, និងគ្រប់កន្លែងទូទាំងប្រទេស
តម្លៃល្អបំផុត ! ស្រស់ថ្មីបំផុត !



អាសយដ្ឋាន 123 Church Street
Lowelll, MA 01852
អតីតផ្សារចាត់ដំបង

Grand Openning
Sale with
the 10%OFF



# ដំណើរពីអាមេរិកទៅអាស៊ី



**ដោយ : ពិន សំខុន**

ខ្ញុំនៅសហរដ្ឋអាមេរិកប្រមាណជាង១០ឆ្នាំចុងក្រោយនេះមិនដែលបានត្រឡប់ទៅស្រុកកំណើតម្តងណាទេ មិត្តភ័ក្រ្តជាច្រើនតែងប្រាប់ថាបើទៅស្រុកខ្មែរពេលនេះមើលស្រុកមិនស្គាល់ទេ ដំណឹងរបៀបនេះរឹតតែធ្វើឱ្យខ្ញុំចង់ទៅលេងស្រុកខ្មែរកាន់តែខ្លាំងឡើងថែមទៀត។ ចុងបញ្ចប់ឱកាសទៅលេងស្រុកខ្មែរក៏មកដល់ដោយសារកូនស្រីពៅគេចង់រៀបចំពិធីមង្គលការតាមប្រពៃណីខ្មែរនៅស្រុកខ្មែរយើងជាឪពុកក៏ត្រូវតែសម្របសម្រួលតាមកូនតែប៉ុណ្ណោះ ។ តាមពិតទៅការសម្របសម្រួលតាមកូននេះក៏ជាគោលបំណងរបស់ខ្ញុំដែលចង់ៈ ឃើញកូនខ្លួនរៀបការឱ្យបានពេញមុខស្របច្បាប់នឹងស្របប្រពៃណីជាប្តីប្រពន្ធខ្លាំងណាស់ដែរ ខ្ញុំតែងតែបញ្ចុះបញ្ចូលកូនស្រីទាំងអស់ឱ្យគិតគូររៀបការតាមប្រ-ពៃណី ពីព្រោះជាចំណងគ្រួសារដែលរឹងមាំបានយូរអង្វែងជាងការចាប់ដៃគូរស្រករស់នៅស្ងាត់ៗ តែខ្លួនឯងដូចដែលវប្បធម៌ក្មេងៗសម័យថ្មីគេតែងធ្វើនៅប្រទេសសេរីនេះ។ បានឃើញកូនផ្តួចផ្តើមគំនិតនេះទៅហើយនោះ ក៏ប្រញាប់យល់ព្រមត្រៀមខ្លួនចូលរួមជាមេបាបំពេញមុខកូនភ្លាម ។

កូនស្រី សម្លាញមីរាតី និង ជែរី យុវជនជាតិបារាំងនឹងរៀបការតាមប្រពៃណីខ្មែរនឹងនៅចំពោះព្រះភ័ក្រ្តព្រះមហាក្សត្រខ្មែរ ថ្ងៃទី ២៤ តុលាឆ្នាំ ២០១៤ ។ ភ្ញៀវទាំងខាងប្រុសទាំងខាងស្រីសុទ្ធតែជាមិត្តភ័ក្រ្តនឹងជាមេបាកូនក្រមុំកូនកម្លោះប្រញាប់ជិះយន្តហោះធ្វើដំណើរពីប្រទេសមហាអំណាចទៅកាន់កម្ពុជាតាមបំណងប្រាថ្នាកូន និងជាឱកាសបានឃើញមាតុប្រទេសកម្ពុជាជាឫសគល់ដ៏ល្បីល្បាញផងមានតែម្តាយ មី៉រាតី ទេ ដែលនៅភ្នំពេញហើយជាស្រេចមិនចាំបាច់ទៅណាឆ្ងាយទេ។ ហេតុអ្វីក៏ការកូននៅឯវាំងទៅវិញ? ខ្ញុំសូមឆ្លៀតឱកាសនិយាយដោះពីចម្ងល់នេះបន្តិច មី៉រាតី គឺជាកូនស្រីទីបីពៅរបស់ខ្ញុំជាមួយភរិយាមុនឈ្មោះស៊ីសុវត្តស៊ីលវីយ៉ាជាព្រះញាតិវង្សហើយបានស្គាល់ព្រះមហាក្សត្របច្ចុប្បន្នតាំងតែពីនៅជាព្រះអង្គម្ចាស់

**តទៅទំព័រទី ០៤**



នៅ បូស្តុន



នៅ ឈីកាហ្គោ



# នាំកូនរៀនការទៅចូលគាល់...


ព្រះមហាក្សត្រ និងម្ដាយកូនស្រី


សាវនាការព្រះមហាក្សត្រជាមួយនឹងក្រុមគ្រួសារ


ព្រះមហាក្សត្រទទួលឪពុករបស់កូនស្រី

នាំកូនស្រីនាម មីរ៉ាដី នឹងកូនប្រសារនាម ផារិ មានឪពុកឈ្មោះ សែ៊ក គ្លាស នាយទាហ៊ានបារាំង នឹងភរិយានាមប្រ៊្វង់ស្វាស៏ឱ្យចូលក្រាបបង្គំគាល់ ដើម្បីព្រះអង្គប្រទានពរដល់គូរស្វាមីភរិយា ក្នុងនាមជាព្រះរាជវង្ស កាលពីថ្ងៃទី២៤តុលាឆ្នាំ២០១៤ វេលាម៉ោង១១ព្រឹក នៅព្រះបរមរាជវាំង។

ភ្ញៀវជាសាច់សារលោហិតប្រមាណ២០រូបបានចូលក្រាបបង្គំគាល់ដឹកនាំប្រតិភូដោយអ្នកអង្គម្ចាស់ ស៊ីសុវត្ថ ស៊ីរីយ៉ា ព្រះអង្គបានសំដែងការអបអរសាទសព្វព្រះរាជហឫទ័យប្រទានពរជ័យដល់គូរស្វាមីភរិយាថ្មីថ្មោង ព្រមទាំងប្រទានវត្ថុអានុស្សាវរីយ៏មានផ្ដិលប្រាក់នឹងថាសប្រាក់ផង។ ក្នុងសវនាការនោះព្រះមហាក្សត្របានអនុញ្ញាត្តិឱ្យតាំងសំនួរដែលអាចមាន លោក សែ៊ជ គ្លាស បានសម្ដែងការអរគុណដែលបានរាជានុញ្ញាត្តិឱ្យក្រុមគ្រួសារចូលថ្វាយបង្គំគាល់ ព្រះអង្គបានឱ្យដឹងតាមរយៈសំនួរ ពិន សំខុន ថា ព្រះខាន់ នឹងម្កុដរាជ្យបានត្រូវគេធ្វើទារុណកម្មដល់ព្រះអង្គម្ចាស់នរោត្ដម កន្ទុល ដែលជាអ្នកថែរក្សាវត្ថុព្រះរាជទ្រព្យចុងក្រោយគេ គេវាយដំដើម្បីជំរីតយកវត្ថុទាំង២ទៅលក់ ឥឡូវវត្ថុទាំង២នៅផ្ទះឯកជន។ ក្នុងបរិយាកាសជាគ្រួសារ ព្រះមហាក្សត្របានបើកឱ្យមានការថតរូបអនុស្សវរីយជាមួយព្រះអង្គទៀតផង។

នៅមួយសប្ដាហ៏មុនខួបទី១០នៃរជ្ជកាលព្រះអង្គព្រះបាទសីហមុនីបានផ្ដាំផ្ញើរនៅពេលដឹងថា សូបិន ជានារីខ្មែរកម្ពុជា ក្រោម "អាណិត ណាស់! សូមផ្ញើរសេចក្ដីនឹករលឹកដ៏ជ្រាលជ្រៅដល់កូនចៅនៅឯនាយពីសម្ដេចព្រះមាតានឹងពីខ្លួនខ្ញុំ" ដោយព្រះភ័ក្ត្រស្រពាប់ស្រពោន ។ ពិធីសវនាការបានចប់នៅម៉ោង១២ថ្ងៃត្រង់ភ្ញៀវទាំងអស់បានថ្វាយបង្គំលាព្រះមហាក្សត្រយ៉ាងអាឡោះអាល័យ ហើយព្រះអង្គលើកព្រះហត្ថលាក្រុមគ្រួសារព្រះអង្គពីជើងជណ្ដើរព្រះរាជដំណាក់ រហូតដល់រថយន្តឆ្លងក្លោងទ្វារព្របរមរាជវាំងផុត៕

**ខ្មែរផុស ស.រ.អា.**











GRAND OPENING
Friendly Insurance
We serve: Auto, Home, Business owners, Flood Insurance



We do: Tax, Payroll, IRS Audit Representation
We are: License to Practice before the IRS, Enrolled Agent, IRS Certified Acceptance Agent
2 Convenient Locations To Serve You:
LOWELL
42 Branch St
(978)452-3800
LYNN
471 Western Ave
(781)593-4344
Office Hours: Mon- Fri 9 - 6 pm, Sat 9 - 2 pm
Visit us at www.friendlyins.com

តមកទំព័រទី ១

# ដំណើរពីអាមេរិកទៅអាស៊ី

កាលនោះព្រះអង្គគង់ជាឯកអគ្គរាជទូតប្រចាំយូណេស្កូនាទីក្រុងប៉ារីសមកម្លេះ ។ ព្រះអង្គធ្លាប់ឱ្យជាជំហ៊ររយ៉ាងមាំដល់ ស៊ីលវិយ៉ា នឹងកូនស្រីទាំងបីក្នុងការទ្រទ្រង់សកម្មភាពមនុស្សធម៌ជួយកុមារកំព្រាកម្ពុជាពីប្រទេសបារាំងមកតាំងពីអម្លុងឆ្នាំ១៩៩៤មកទល់សព្វថ្ងៃនេះ។ ជាអកុសលខ្ញុំនឹងស៊ីលវិយាមិនបានរស់នៅជាមួយគ្នាចែកផ្លូវគ្នាតាំងពីឆ្នាំ១៩៨៨មកម្លេះ ។

ថ្ងៃទី ៩តុលា ២០១៤មេឃស្រឡះល្អខ្ញុំនឹងភរិយាសុបិន្តរៀបចំដំណើរយ៉ាងហត់នឿយឥតបានដេកពួនមួយយប់ពេញពីព្រោះជាប់រវល់ធ្វើការឱ្យកុំប៉ានីរហូតដល់នាទីចុងក្រោយចុងបញ្ចប់ទីក្រុងចិនកុម្មុយនិស្តក៏សាងជាក្រុងសេដ្ឋកិច្ចទំនើបដោយចក្រភពអង់គ្លេសដែលបានត្រួតត្រាលើដែនដីចិននេះចំនួន១០០ឆ្នាំ ។ យើងបានមកដល់ចំពេលដែលប្រជាជនចិនតំបន់ហុងកុងនេះចុះធ្វើបាតុកម្មគគ្រឹកមេឃគគ្រឹកដីជាងមួយអាទិត្យហើយទាមទារមិនឱ្យចិនដីគោកកុម្មុយនិស្តបេយើងលូកដៃដ៏មានអំណាចរបស់ខ្លួនមកលើការគ្រប់គ្រងតាមបែបសេរីរបស់ចិនហុងកុងបើទោះជាបេឃើងជាម្ចាស់ទឹកម្ចាស់ដីក៏ដោយ ។ ការពិតទៅយើងមិនបានឃើញអ្វីទាំងអស់ ក្រៅតែពីចិននៅក្រុមហ៊ុនយន្តហោះកាតេផាសវិហ្វិកជាតហោយភាចិចិច នឹងនៅវាលយន្តហោះដ៏ធំសម្បើមនៃមិននិយាយរហូតជិតដល់ហុងកុងពេលស្រីចំណាស់នោះភ្ញាក់ ក៏សួរនាំទោះ ទើបគាត់ឱ្យមកវិញ។

នៅព្រលានយន្តហោះហុងកុងដែលខ្ញុំខានជួបជាង១០ឆ្នាំមកហើយ ឥឡូវរីកដុះដាលកាន់តែធំធ្វើឱ្យខ្ញុំដែលនឿយហត់មិនបានដេកពួនផងនោះត្រូវដើរច្រើនម៉ាយទុំរាំដល់ជើងដំណើរយន្តហោះចេញមួយទៀត ។ បន្ថែមពីលើនេះនៅលើសំបុត្រយន្តហោះគេភ្លេចមិនបានចារុលេខទ្វារជើងដំណើរឱ្យយើងហើយនៅមុនពេលចុះពីយន្តហោះមកដល់ហុងកុងក៏គេមិនបានផ្សាយពីតំណរភ្ជាប់លេខជើងយន្តហោះចេញឱ្យយើងទៀត យើងដើរ១០នាទីហួសទ្វារដែលយន្តហោះយើងចេញការពិតយើងរកអ្នកដែលឆ្លើយនឹងសំនួរយើងមិនបានសោះយើងទៅខុសកន្លែងដល់មកវិញពេលដឹងថាច្រកទ្វារលេខប៉ុន្មានហើយត្រឡប់មកវិញយន្តហោះបានចេញចោលផុតទៅហើយពេលនោះហត់ទាំងឪទាំងម៉ែ ហើយភាពមួរម៉ៅក៏ផ្ដើមដែរតែកូនវាឥតហត់សោះហើយរត់ជួយរុញឥវ៉ាន់ពួកយើងឥតឈប់ដែរ ។ ចុងបញ្ចប់យើងរកការិយាល័យក្រុមហ៊ុនយន្តហោះកាថេឃើញ គឺប្តូរសំបុត្រជើងយន្តហោះបន្ទាប់យឺតពេល១ម៉ោងបានសំបុត្រថ្មីហើយ យើងដើរ១០នាទីទៀត ទើបដល់ទ្វារយន្តហោះថ្មីនោះទាន់ពេលត្រឹមគេផ្ដើមបិទទ្វារល្ហម ។ នឹកត្រឡប់មកវិញឃើញថា អ្នកបំរើព្រលានយន្តហោះចិនមិនចេះសើចញញឹមទទួលភ្ញៀវទេ ពួកគេមិនត្រឹមតែមិនឆ្លើយសំនួរទេ ថែមទាំងដេញយើងឱ្យទៅមើលក្ដារឃៀនអេឡិកត្រូនិកដោយខ្លួនឯងក្ដារឃៀននោះមានអក្សរនឹងលេខដែលលោតលឿនអក្សរចិនលាយនឹងអងគ្លេសមើលធ្វើឱ្យឈឺក្បាលព្រោះមើលស្ទើរមិនទាន់ហេតុនេះហើយសូបិននិយាយថាអ្នកទទួលភ្ញៀវចិននៅឈីកាហ្គោមិនដូចចិននៅហុងកុងនេះទេនៅខាងអាមេរិកឯណោះគេធ្វើអ្វីៗគ្រប់យ៉ាងដើម្បីទាក់ចិត្តភ្ញៀវរីឯនៅហុងកុងវិញគេមានចារឹកដូចជាមន្ត្រីដែលមានភ្ញៀវជាអ្នកស្ដាប់បង្គាប់អ៊ីចឹង។ នៅហុងកុងសម្បូរទេសចរធ្វើដំណើរដោយមានអ្នកដឹកនាំទៅជាមួយកាន់ទុងជ័យពណ៌ក្រហមនាំមុខភ្ញៀវកាន់ទាំងលិខិតឆ្លងដែនជូនភ្ញៀវទៀតនេះជា

តទៅទំព័រទី ១៤



នៅ ឈីកាហ្គោ រៀបចេញដំណើរទៅហុងកុង



ក៏បានចេញដំណើរតាមយន្តហោះ"AAអេអេ American Airline" ពី Boston បុស្តុន នៅម៉ោង១០ព្រឹក មកកាន់ Chicago ឈីកាហ្គោនៅម៉ោង១កន្លះ រីឯអ្នកដែលសប្បាយរីករាយជាគេ គឺ ប៉ុណ្ណារ៉ូ ដែលតាំងពីព្រលឹមព្រាងៗនិយាយនឹងលេងច្រើនឥតឈប់ឈរធ្វើឱ្យយើងជាឪពុកម្ដាយតាមចាប់ស្ទើរមិនឈ្នះ។ យន្តហោះប៊ូអ៊ីងដែលមានចំណុះភ្ញៀវរវពេញប្រមាណ៣០០នាក់អង្គុយយ៉ាងចង្អៀតណែនក្បែរអ្នកដំណើរគ្រប់ប្រភេទមិនដឹងនរណាជានរណាទេយើងមិនចាំបាច់ស្លៀកពាក់ជាមនុស្សសំខាន់អ្វីទៀតទេឥឡូវនេះដំណើរតាមយន្តហោះគ្រាន់តែជាជំនិះរបស់មនុស្សតែប៉ុណ្ណោះបើចង់ក្លាយជាមនុស្សសំខាន់គេត្រូវទិញសំបុត្រយន្តហោះថ្នាក់ទី១ ឬទី២ ទើបមានការយកចិត្តភ្ញៀវតាមឋានៈជាមនុស្សសំខាន់បាន ដូច្នេះគឺចំនួនលុយទេ ដែលអាចចង្អុលបង្ហាញថា មនុស្សណាជាអ្នកសំខាន់នោះ ។ នៅឈីកាហ្គោយើងរង់ចាំជើងដំណើរបន្តរហូតដល់ម៉ោង៣កន្លះរសៀល ទើបចេញដំណើរបន្តទៅកាន់បាងកក Bangkok នៃប្រទេសថៃជាបន្តទៅទៀត។ ម្ដងនេះយើងជិះយន្តហោះខ្នាតធំជាងគេបង្អស់ គឺប៊ូអ៊ីង៧៤៧ ដាក់ភ្ញៀវនឹងបុគ្គលិកបានជាង៥០០នាក់...ជាថ្មីម្ដងទៀត ខ្ញុំសូបិន និងកូនអាយុ៤ឆ្នាំកន្លះអង្គុយថ្នាក់ទី៣ យ៉ាងគួរឱ្យអាណិតខ្លួនលើកៅអីតូចចង្អៀតរើខ្លួនមិនរួចចំនួន១៤ម៉ោង មុននឹងដល់ដំណាក់សម្រាកប្ដូរយន្តហោះនៅហុងកុងក្រុងហុងកុងខ្ញុំបានសួរទៅនារីធ្វើការក្នុងយន្តហោះដ៏ស្រស់ស្អាតម្នាក់ថា តើហុងកុងនៅតែរីកវរនៅឡើយទេ ឬក៏ស្ងប់ស្ងាត់ទៅហើយ? នាងតបដោយញញឹមហើយញាក់ស្មាផងថា ខ្ញុំឥតដឹងដែរ ពីព្រោះខ្ញុំចេញមកធ្វើការ២ថ្ងៃហើយ...ប៉ុណ្ណារ៉ូឃើញខ្ញុំនិយាយជាមួយស្រីចិនក៏ចូលជិតហើយសួរថាប៉ាចេះនិយាយភាសាចិនឬ? ពីព្រោះមុននេះបន្តិចខ្ញុំបានប្រាប់គេថា ចិនគេនិយាយភាសាចិនយន្តហោះនេះក៏ជារបស់ចិននៅហុងកុងដែរ ខ្ញុំក៏ឆ្លើយនឹងសំនួរនេះថា ស្រីចិននោះគេនិយាយជាមួយប៉ាជាភាសាអាមេរិកាំង! គួរឱ្យចង់សើចកូនវាឱទ្ទានថា អូ! រួចក៏ដើរចេញទៅ។

នឹកដល់រឿងចិនដែលធ្លាប់លូកដៃដ៏ក្រខ្វក់មកជួយមនុស្សមួយក្ដាប់តូចនៅស្រុកខ្មែរថា ហុងកុងមានអធិបតេយ្យក្នុងការគរប់គ្រងតាមគំរូអង់គ្លេសដដែលចំនួន៥០ឆ្នាំទៀត បន្ទាប់ពីបេយើងកាន់កាប់ដីវិញតែបេឃើងចាប់ផ្ដើមដាក់ដង្កៀបលើហុងកុងដែលប្រជាពលរដ្ឋមិនអាចទទួលយកបាននៅឡើយ ។

ដោយនឿយហត់ខ្លាំងក៏យកក្មើយរុំកមកពាក់ហើយដេកលក់ទៅប្រមាណ១ម៉ោងក្រោយមកមានគេដាស់បំរើបាយល្ងាចក្មើយរុំកក៏បាត់រកជុំវិញមិនឃើញសោះមានស្រីចិនចំណាស់ម្នាក់រូបក៏អាក្រក់យកក្មើយខ្ញុំដែលបានធ្លាក់ពេលខ្ញុំដេកលក់យកទៅប្រើសំរាប់គាត់ដេកយ៉ាងរំភើយរហូតដល់ហុងកុងសូបិនបានសង្កេតរឿងនេះ តែ



# ផលិតករភាពយន្ត "រឿងវាលពិឃាត" សរសើររដ្ឋាភិបាលកម្ពុជា

**Cambodia Daily**

**ដោយ ៖ អេឡិក វិល្លឹមមីនស៍ AND មុិច ដារ៉ា** | **MARCH 7, 2014**

លោក ដេវីដ ពុធ ណាម ដែលបានផលិតភាពយន្ត"រឿងវាលពិឃាត" កាលពីឆ្នាំ១៩៨៤ និងឥឡូវនេះគឺជាបេសកជនពាណិជ្ជកម្មរបស់ប្រទេសអង់គ្លេសប្រចាំកម្ពុជានោះបានកោតសរសើររដ្ឋាភិបាលកាលពីម្សិលមិញ ចំពោះការប្តេជ្ញារបស់ខ្លួនក្នុងការលុបបំបាត់អំពើពុករលួយ ហើយលោកបានអំពាវនាវឱ្យប្រព័ន្ធផ្សព្វផ្សាយដើរតួនាទីស្ថាបនាថែមទៀតនៅពេលដែលរដ្ឋាភិបាលបីង្រប្រែងអភិវឌ្ឍប្រទេស។



លោក ពុធ ណាម បានថ្លែងនៅពេលពិសាអាហារថ្ងៃត្រង់ដែលរៀបចំឡើងដោយសភាពាណិជ្ជកម្មអង់គ្លេសប្រចាំកម្ពុជានៅថ្ងៃទី៣ និងជាថ្ងៃចុងក្រោយនៃដំណើរទស្សនកិច្ចរបស់លោកថា រដ្ឋាភិបាលកម្ពុជាបានប្រើប្រាស់វិធីសាស្ត្រគួរឱ្យកោតសរសើរក្នុងការលុបបំបាត់អំពើពុករលួយ ដែលផ្តោតលើការកែប្រែឥរិយាបថ និងតម្លៃរបស់មនុស្ស។

លោក ពុធ ណាម បានប្រាប់អ្នកចូលរួមប្រហែល៥០នាក់ថា "ខ្ញុំមិនគិតថា ខ្ញុំបានទៅកន្លែងណាមួយដែលខ្ញុំបានទទួលការឆ្លើយតបពេញលេញពីរដ្ឋាភិបាលអំពីបញ្ហាទប់ស្កាត់ និងលុបបំបាត់អំពើពុករលួយនោះទេ"។

"ខ្ញុំមើលឃើញមានការប្តេជ្ញា និងការតាំងចិត្តនៅទីនេះដើម្បីទប់ស្កាត់អំពើពុករលួយ ហើយការស្វែងរកឫសគល់របស់វា គឺជាការសំខាន់ណាស់។ ចាប់ពីពេលនេះទៅក្នុងរយៈពេលប្រាំឆ្នាំទៀត ខ្ញុំប្រហែលជាត្រូវគេគិតថា ជាមនុស្សភ្លើ ប៉ុន្តែខ្ញុំមិនគិតថា ខ្ញុំជាមនុស្សបែបនេះទេ ខ្ញុំមិនគិតថា ខ្ញុំជាមនុស្សបែបនេះឡើយ"។

ឆ្លើយសំណួរបន្ទាប់ពីលោកបាននិយាយពីកេរដំណែលនៃខ្សែភាពយន្តរបស់លោក លោក ពុធ ណាម បានផ្ញើសារតាមនិស្សិតដែលបានចូលរួមទស្សនាការបញ្ចាំងខ្សែភាពយន្តរឿងវាលពិឃាតកាលពីយប់ថ្ងៃពុធ។

លោកបានមានប្រសាសន៍ថា "ខ្ញុំបាននិយាយប្រាប់និស្សិតថា តើពួកគេចូលចិត្តរឿងនេះដែរ ឬអត់ពួកគេនៅតែជាក្មេងនៅក្នុងរឿងវាលពិឃាតជារៀងរហូត។ អ្វីដែលពួកគេត្រូវសម្រេច គឺថាតើរឿងវាលពិឃាតជារឿងមួយដែលបង្ហាញពីការផ្លាស់ប្តូរដ៏សំខាន់មួយនៅក្នុងប្រទេសនេះ និងជាជោគជ័យដ៏ធំធេង ឬវានៅតែជាការចងចាំដ៏ខ្មៅងងឹតដែលមិនអាចបំភ្លេចបាន"។

បេសកជនពាណិជ្ជកម្មរូបនេះក៏បានបញ្ជាក់ពីមូលហេតុ **តទៅទំព័រទី ២៩**



# គិលានុបដ្ឋាពីររូបត្រូវឆ្លងជំងឺអេបូឡា

**ដកស្រង់ដោយ : ថាច់ វណ្ណា**

សប្តាហ៍កន្លងហើយកាសែតខ្មែរផុសស.រ.អាបានរៀបរាប់ពីដំណើរដើមទងរបស់មេរោគអេបូឡាឆ្លងចូលស.រ.អាតាមរយៈលោក ដាន់ កែវ មកពីទ្វីបអាហ្វ្រិក លោក ដាន់ កែន បានស្លាប់ក្នុងមន្ទីរពេទ្យជ្រែសបៃតើ រៀន "Presbyterian"នៅទីក្រុងដាឡាស រដ្ឋថិកស៊ីស ជំងឺនេះ បានឆ្លងទៅលើខ្លួនគិលានិបដ្ឋាពីររូបក្នុងករណីព្យាបាលជំងឺអេបូឡាឱ្យលោក ដាន់ កែន ។

-គិលានុបដ្ឋាទី១ ដែលត្រូវឆ្លង មេរោគ គឺ នីណា ផាម, (NINA Phan) អាយុ២៦ឆ្នាំ ត្រូវបានបញ្ជូនចេញទៅមន្ទីរពេទ្យ"NIH"វិទ្យាស្ថានសុខភាពជាតិនៅក្រុងបែតធិសដា"Bethesda" ក្នុងរដ្ឋមារីឡិន កាលពីថ្ងៃទី១៦ ខែ តុលា ឆ្នាំ ២០១៤ ។

-គិលានុបដ្ឋាទី២ ដែលបានឆ្លងមេរោគ គឺ អែម-ប៊ី-ជយ-វិន-ស៊ីន "Naber Joy Vinson"អាយុ២៩ឆ្នាំ ត្រូវបានបញ្ជូនចេញពីដាឡាស ទៅមន្ទីរពេទ្យមណ្ឌលជីវសមាសធាតុជំងឺឆ្លងនៅទីក្រុងអាតឡានតា"Atlana"ញូជើស៊ី "New Jersy"ស្ថានភាពព្យាបាលជំងឺដល់ពេទ្យគិលានុបដ្ឋាយិកាទាំងពីររូប មានភាពប្រសើរជាងពេលដែលព្យាបាលឱ្យលោក ដាន់ កែន ។ ព្រោះថា គេអាចទប់ស្កាត់មិនឱ្យជំងឺមិនឱ្យលូតលាស់បាន តាមធម្មតា អេបូឡា អាចបណ្តាលឱ្យមនុស្សស្លាប់ក្នុងរយៈពេល៩ថ្ងៃ ឬ១២ថ្ងៃប៉ុណ្ណោះ ។

មកទល់ពេលនេះអ្នកជំងឺទាំងពីរនាក់ បានស្ថិតករណីព្យាបាលបីសប្តាហ៍កន្លងគេឃើញមានសញ្ញាធូរស្រាលជាងមុន ។

ទោះបីជាយ៉ាងនោះក៏ដោយ ពុំមានការបញ្ជាក់ច្បាស់លាស់ ថាតើអ្នកទាំងពីរបានឆ្លងមេរោគអេបូឡាប្រភេទណានោះទេ ។

**មេរោគអេបូឡាមាន៥ប្រភេទ គឺ :**

១-Ebola-Zaire : អេបូឡា សៃ ។

២-Ebola-Sudan : សូដាន់

៣-Ebola-Ivory Coast : អៃវ៉ូរី ឃុស

៤-Ebola-Bundibug yo :ប៊ីនឌិកយ៉ូ

៥-Ebola-Reston : រ៉េស តឹន

ក្នុងចំណោមអេបូឡាទាំង៥ គឺមាន៤ មានដើមកំណើតពីទ្វីបអាហ្វ្រិក មាន១ គឺ Ebola-Reston អេបូឡា រ៉េសតឹន មានដើមកំណើតនៅប្រទេសភីលីពីន"Philipines" ។

តាមពណ៌អង្គការសុខភាពពិភពលោកតក់ត្រាបញ្ហាជំងឺអេបូឡាបានឱ្យដឹងថាៈ គិតមកដល់ថ្ងៃទី១៤ តុលា ឆ្នាំ២០១៤ មានប្រទេសចំនួន៧ទូទាំងពិភពលោកត្រូវឆ្លងជំងឺនេះ ។

១-Guirea : ហ្គេនីអា មានៈ ១ពាន់ ២រយ ៦២នាក់ ត្រូវឆ្លងជំងឺ,មាន៨រយ៦២នាក់ត្រូវស្លាប់ ។

២-Liberia: លីបេរីអា មាន៤ពាន់២រយ ៦២នាក់ត្រូវឆ្លងជំងឺ,មាន២ពាន់៤រយ៨៤នាក់ត្រូវស្លាប់ ។

៣-Nigeria: និរចិរៀ មាន២០នាក់ឆ្លងជំងឺ,មាន៨នាក់ត្រូវស្លាប់ ។

៤-Serengal: ស៊ីនើហ្គាវ , មានម្នាក់ឆ្លងជំងឺពីប្រទេស "Guirea"ហ្គេនិអា ប៉ុន្តែមិនស្លាប់

៥-Sirra Leone : សៀរ៉ា លីអន, មាន៣ពាន់៤រយ ១០នាក់ ឆ្លងជំងឺ, មាន១ពាន់២រយនាក់ត្រូវស្លាប់ ។

៦-ប្រទេស Spain : ស្ប៉ែន , មានម្នាក់ប៉ុន្តែមិនស្លាប់

៧-ស.រ.អា មាន៣នាក់ ឆ្លងជំងឺមានម្នាក់ស្លាប់ គឺ ដាន់ កែន ដែលបានឆ្លងជំងឺមកពីប្រទេសលីបេរៀ "Liberia" ៕

**WHO: EBOLA RESPONSE ROADMAP UPDATE**
**17 October 2014**

World Health Organization

A total of 9216 confirmed, probable, and suspected cases of Ebola virus disease (EVD) have been reported in seven affected countries (Guinea, Liberia, Nigeria, Senegal, Sierra Leone, Spain, and the United States of America) up to the end of 14 October. There have been 4555 deaths. A second EVD-negative sample was obtained from the single confirmed case in Senegal on 5 September (42 days ago). WHO officially declares the Ebola outbreak in Senegal over. Following the WHO Ebola Response Roadmap structure[1], country reports fall into two categories: 1) those with widespread and intense transmission (Guinea, Liberia, and Sierra Leone); and 2) those with an initial case or cases, or with localized transmission (Nigeria, Senegal, Spain, and the United States of America). An overview of the situation in the Democratic Republic of the Congo, where a separate, unrelated outbreak of EVD is occurring, is also provided (see Annex 1).

**1. COUNTRIES WITH WIDESPREAD AND INTENSE TRANSMISSION**

9191 (probable, confirmed and suspected; see Annex 2) cases and 4546 deaths from EVD have been reported up to the end of 13 October 2014 by the Ministry of Health of Liberia, and 14 October by the Ministries of Health of Guinea and Sierra Leone (table 1).

**Table 1: Ebola virus disease cases and deaths in Guinea, Liberia, and Sierra Leone**

| Country | Case definition | Cases | Deaths |
|---|---|---|---|
| Guinea | Confirmed | 1217 | 671 |
| | Probable | 191 | 191 |
| | Suspected | 111 | 0 |
| | **All** | **1519** | **862** |
| Liberia | Confirmed | * | * |
| | Probable | * | * |
| | Suspected | * | * |
| | **All** | **4262** | **2484** |
| Sierra Leone | Confirmed | 2977 | 932 |
| | Probable | 37** | 161** |
| | Suspected | 396 | 107 |
| | **All** | **3410** | **1200** |
| **Total** | | **9191** | **4546** |

**Stratified data are temporarily unavailable for Liberia. **For Sierra Leone, 124 more probable deaths have been reported than have probable cases. Data are based on official information reported by Ministries of Health up to the end of 14 October 2014 for Guinea and Sierra Leone, and 13 October 2014 for Liberia. These numbers are subject to change due to on-going reclassification, retrospective investigation and availability of laboratory results.*

1 The Ebola Response Roadmap is available at: http://www.who.int/csr/resources/publications/ebola/response-roadmap/en/.





**ទស្សនៈ ពុធ សុខសាន**

នៅលើពិភពលោកយើងនេះ មានរឿងរ៉ាវច្រើនរាប់មិនអស់ បើអ្នកធ្វើជំនួញអាចដឹងពីចរាចរតម្លៃអចលនៈទ្រព្យគ្រប់យ៉ាងនៅគ្រប់ប្រទេសដែលរីកចម្រើនផ្នែកជំនួញ ។ ចំណែកកម្ពុជាយើងថ្នាក់ដឹកនាំប្រទេសខ្មែរមួយថ្ងៃៗរវល់តែតាមដានរឿងភាគចិន សាមកុកពីល្បិចស្នៀតការពារអំណាចខ្លាចបាត់បង់ ទើបមិនដឹងពីប្រជាជនខ្មែរវេទនាល្បីពេញពិភពលោកអង្គការសហប្រជា

# តើពលរដ្ឋជ្រើសយកនរណា?



ជាតិប្រទេសលោកសេរី គេគិតគួរផ្តល់ជំនួយរាប់ម៉ឺនលានដុល្លារចង់ឱ្យរាស្ត្រខ្មែរបានសុខបានសប្បាយដូចប្រទេសគេដែរ ។ តែបច្ចេកវិទ្យាទំនើបវិទ្យាសាស្ត្រជឿនលឿនសង្គមហ្វេកប៊ុកបង្ហាញអ្នកចូលចិត្តតាមដានព័តិមានសន្តិសុខសង្គមអាចដឹងរឿងនយោបាយគ្រប់ប្រទេស បើចង់តាមដានរួមទាំងប្រទេសខ្មែរផង ។

គួរឱ្យគិតពីរឿងចម្លែកថ្នាក់ដឹកនាំប្រទេសទាន់ចិត្តមិនបានទាក់ទាញនាយករដ្ឋមន្ត្រីខ្មែរឱ្យបានឃើញរាស្ត្រខ្មែរវេទនាអស់ទឹកអស់ដីអស់ផ្ទះ តវ៉ាត្រូវជាប់គុកច្រវ៉ាក់ បែកម្តាយ ឪពុក ប្រពន្ធ កូន ឆ្លងដែន ស្វែងរកការងារធ្វើត្រូវគេបោកប្រាស់ទាំងនៅក្នុងប្រទេស និងនៅក្រៅប្រទេស ។

គិតទៅសោកនាដកម្មដែលរាស្ត្រខ្មែរបានទទួល គឺគ្មានសង្គមណាអាចប្រៀប នឹងសង្គមនេះបានទេ ទំហំទុក្ខវេទនាធ្វើឱ្យគាត់លែងចង់រស់ ព័តិមានសង្គមមួយថ្ងៃចងក លេបថ្នាំ លោតទឹកសម្លាប់ខ្លួនមានមួយពីរ ថ្ងៃខ្លះមានដល់បី ទោះបីជំនាន់ខ្មែរក្រហម ឮស្លាប់អត់បាយ ស្លាប់នឹងលាបពណិយកទៅសម្លាប់មិនដល់ថ្នាក់វេទនាលែងចង់រស់ដូចសង្គមនេះទេ ។

ដល់ពេលមកឮនាយករដ្ឋមន្ត្រីសារភាពមិនដឹងប្រជាជនស្រែកយំត្រូវអ្នកមានអំណាចរំលោភអស់ដីស្រែចំការ ផ្ទះសម្បែងវាទៅជារឿងគួរហួសចិត្ត ។

ព្រោះតែយ៉ាងណឹងតើ បានជាប្រទេសខ្មែរជួបរឿងលំបាកវេទនាល្បីពេញពិភពលោកមកពីអ្នកដឹកនាំប្រទេសមិនទទួលខុសត្រូវ តួនាទីខ្លួនជាថ្នាក់ដឹកនាំមានទស្សពិតរាជធម៌ ដែលរាស្ត្រមួយនគរខ្មែរផ្ញើរវ៉ាសនាលើខ្លួន ។

សួរថា បើថ្នាក់ដឹកនាំមានសន្ដានបែបហ្នឹង ហើយគាត់នៅតែព្យាយាមក្រាញ់អំណាច ដោយមិននឹកឃើញខ្មាស់អៀន នៅមានអ្នកគាំទ្រគាត់ទៀត តើអ្នកគាំទ្រនោះ មានចិត្តមេត្តា នៅក្នុងខ្លួនដែរឬទេ ?

ចាប់ពីពេលនេះទៅពលរដ្ឋខ្មែរ ក្នុងប្រទេស និងនៅលើពិភពលោកគាត់ស្គាល់ច្បាស់ ហើយអ្វីជាអ្វី ទើបគណបក្សសង្គ្រោះជាតិអាណត្តិទី៤ នេះសល់ពីលួចឈ្នះ២៦កៅអី បានអាសនៈនៅក្នុងរដ្ឋសភា៥៥អាសនៈ ៕







# កម្រងអនុស្សាវរីយ៍ អាល់ប៊ុមរូបថត

## ថ្ងៃចូលគាល់ព្រះមហាក្សត្រខ្មែរ ថ្ងៃទី ២៤ តុលា ២០១៤ ក្នុងពិធីរៀបមង្គលការ មីរ៉ាដី និង ធារី















តមកទំព័រទី ១

# បើសហគមន៍ខ្មែរចង់ខ្លាំងត្រូវទៅបោះឆ្នោត

ច្រើនជាងគេបង្អស់នៅឡូងប៊ិចមានទំហ៊ុំតែ៣ភាគរយតែប៉ុណ្ណោះ។ តែមកដល់ថ្ងៃនេះបែរជាខកខានមិនបានប្រើកម្លាំងឱ្យបានជាប្រយោជន៍ដល់ខ្លួនឯងនឹងក្រុមគ្រួសារញាតិមិត្តបាននៅឡើយទេតើហេតុអ្វី?

**ខ្មែរមិនចេះប្រើឧបករនៃលទ្ធិប្រជាធិប-តេយ្យ :**

ខុសគ្នានឹងប្រទេសកម្ពុជាគេមិនអាចលួចសន្លឹកឆ្នោតបានទេតែក៏នៅតែមានអ្នកខ្លះខិតខំបន្លំអ្នកមិនចេះអក្សរជ្រៅជ្រះគូសឈ្មោះបេក្ខជនខ្លួនជំនួសម្ចាស់ឆ្នោតនៅឡើយ ឬក៏មិនទៅបោះឆ្នោតក៏មិនអីពីព្រោះមិនមែនគ្នារបស់អញឈរឈ្មោះឬក៏ខកចិត្តពិអតីតកាលដោយនិយាយថានឹង"បោះឱ្យនរណាក៏ដូចជានរណាដែរ"នោះ... ទាំងនេះគឺជាការភន្តច្រឡំដ៏ធំធេងមួយសម្រាប់ការកសាងកម្លាំងសហគមន៍ឱ្យបានមាំមួន ។ អ្នកបោះឆ្នោតមានឆន្ទៈមួយចង់ឱ្យបេក្ខជនម្នាក់ធ្វើការឱ្យខ្លួនមិនប្រាកដថាបេក្ខជនរបស់ខ្លួនអាចបំពេញបំណងនោះបានទេតែការបង្ហាញឆន្ទៈរបស់អ្នកពុំមែនទៅលើបុគ្គលនោះទេគឺប្រាកដជាសំដៅទៅលើគម្រោងច្បាស់លាស់មួយដែលនឹងត្រូវធ្វើឱ្យបានសម្រេចចាប់ពីពេលដែលបោះឆ្នោតរួចទៅ។ អ្នកត្រូវតែបន្តបង្ហាញផ្លូវដល់បេក្ខជនរបស់អ្នកដោយលើកសន្លឹកឆ្នោតគម្រាមគ្រប់ពេលថាសិទ្ធរបស់អ្នកនៅតែមានសុពលភាពជាដ៏រាបហើយអ្នកដ៏ទៃឯទៀតអាចនឹងបំពេញតួរនាទីជំនួសមន្ត្រីរបស់អ្នកបានដែរ។ ដូច្នេះយើងយល់ស្របទាំងស្រុងនឹងចលនាសមាគមខ្មែរនឹងមន្ត្រីធំតូចនៅឡូវែលនាសប្ដាហ៍នេះដែលសុំអញ្ជើញបងប្អូនខ្មែរឱ្យចេញ ទៅបោះឆ្នោតនៅថ្ងៃទី៤វិច្ឆិកានេះឱ្យបានគ្រប់ៗគ្នាមិនថាបោះឱ្យ "រ៉ាឌីម៉ម ឬ បាហ៊ូ



នោះទេធ្វើយ៉ាងនេះទើបបានជាប្រយោជន៍ដល់សហគមន៍ខ្មែរ ។ រីឯអ្នកមិនទៅបោះឆ្នោតដោយរវល់រកស៊ីដោយដេកភ្លេចភ្ញាក់ដោយមើលងាយសម្លេងនៃការបោះឆ្នោតរួមទាំងហេតុផលមិនចាំបាច់មិនគួររាប់ជាមនុស្សមានការទទួលខុសត្រូវគ្រប់គ្រាន់ចំពោះវាស្នាសហគមន៍ខ្មែរនោះទេ។

សម្លេងឆ្នោតតែ១៣ភាគរយនៃការបោះឆ្នោតបឋមជុំទី១ បានន័យថា មានអ្នកមិនទៅបោះឆ្នោតជាច្រើនបានបង្ហាញដល់សាធារណជនថាបានមើលងាយដល់សម្លេងឆ្នោតខ្លួនឯងដែលពេលបោះឆ្នោតផ្តាច់ព្រាត់ត្រូវតែកែតម្រូវឱ្យបាន



Bahou



Rady mom

មកវិញ។

ខ្មែរឡូវែលខ្វះមគ្គុទេសពិតប្រាកដៈនៅឡូវែលគេនាំគ្នាលាក់បាំងរឿងអាស្រូវក្នុងគ្រួសារខ្មែរថាជារឿងអាក្រក់ដែលមិនត្រូវឱ្យនរណាដឹងឮនឹងជួយដោះស្រាយទេមិនតែប៉ុណ្ណោះថ្នាក់ដឹកនាំកំពូលរបស់យើងមិនព្រមជួយដោះស្រាយវិបត្តគ្រួសារដែលជាទូទៅសហគមន៍ឯទៀតៗ គេពួតដៃគ្នារកធនធានរដ្ឋ ឬឯកជនមកជួយសហគមន៍គេយ៉ាងចំហរកុំឱ្យមានការរំលោភពីសាលារៀនពីមន្ត្រីប៉ូលីសពីការលំអៀងរបស់តុលាការ ។ល។ បើមិនបើកកកាយតើនរណាដឹងរឿងកំសត់របស់ខ្មែរ? នឹងជួយខ្មែររបៀបណា? មគ្គុទេសពិតប្រាកដគេសំគាល់ដោយការសំដែងខុសនឹងត្រូវបង្ហាញជូនពលរដ្ឋដោយមិនខ្លាចការទិទានហើយការទិទាននេះទៀតសោតក៏ជាសម្បត្តសម្រាប់ស្ទង់មតិយកមកបំរើសហគមន៍ដែរ។

បគ្គុទេសដ៏ធំសម្បើម គឺវត្តអារាម២ដែលជាមណ្ឌលប្រៀនប្រដៅពលរដ្ឋកំពុងសំដែងឫទ្ធិបញ្ជាសទិស គឺវត្តឡូវែលនឹងវត្តត្រៃរតនារាមធ្វើឱ្យពលរដ្ឋខ្មែរបែកបាក់ជាពួកជាក្រុមគ្មានអាណិត។ ម្នាក់ៗសុទ្ធតែអ្នកប្រាជ្ញអ្នកគ្មានកំហុសហើយអ្នកដទៃទេដែលមានកំហុសនោះ...ដំណោះស្រាយដែលគ្មានបរិច្ចាកនឹងគ្មានការយោគយល់គ្មានសុច្ចរិតយុត្តធម៌មិនអាចសំរេចគោលដៅប្រយោជន៍ពលរដ្ឋបានទេ។

ដូច្នេះបញ្ហានៅតែដដែលប្រជាពលរដ្ឋត្រូវតែរៀបចំវាសនាខ្លួនដោយខ្លួនឯងចេញទៅបោះឆ្នោតកំណត់ឆន្ទៈថាខ្លួនចងបានអ្វី ? ឆ្លាក់មគ្គុទេសដែលខ្លួនចង់បានឱ្យមានរូបរាងដែលស្លួនស្រឡាញ់ជាមួយសន្លឹកឆ្នោតដែលខ្លួនមានសំណាងនឹងបានទទួលមួយនៅអាមេរិកនេះ។

**ខ្មែរចេះតែបែកបាក់មិនចេះរួបរួមគ្នាទេ :**

សង្គមយើងមានការបែកបាក់ច្រើនមែន! តែប្រយោគនេះមិនច្បាស់ជាឆ្លុះបញ្ចាំងធាតុពិតបានទេ មហាត្ម័កគន្ធីតែម្នាក់បានបង្រួបបង្រួមឥណ្ឌា៣០០លាននាក់ រហូតដល់រំដោះប្រទេសបានឯករាជ្យពីចក្រភពអង់គ្លេសបាន។ ខ្មែរឡូវែលមិនដែលមានឱកាសនឹងទទួលមគ្គុទេសដែលល្អបរិសុទ្ធនៅឡើយសោះគេនិយាយតែពីក្រុមបក្សពួកនៃប្រយោជន៍អញ្ញនិយមដែលមិនអាចបង្រួបបង្រួមនរណាក្រៅតែពីក្រុមអញបានឡើយ។ ខ្មែរឋានជាកម្មករជាម្ចាស់ដីធ្លីតូចតាចជាមន្ត្រីជាន់ទាបនៅកម្ពុជាកំពុងបង្រៀនយើងអំពីវិជ្ជារួមកម្លាំងគ្នាដើម្បីកាពាប្រយោជន៍ជាតិប្តូរអំណាចពីជនផ្តាច់ការ ។ នេះក៏ដោយសារកម្លាំងនៃសន្លឹកឆ្នោតដូចគ្នារាស្ត្របានសម្តែងឆន្ទៈហើយកំពុងឆ្លាក់អ្នកនយោបាយដែលខ្លួនចូលចិត្តទៅតាមឆន្ទៈដែលក្រុមខ្លួនបានកំណត់ទុកជាមុន។

ដូច្នេះការកាន់វាសនាសង្គមខ្លួនឯងគឺជាករណីកិច្ចរបស់ពលរដ្ឋក្នុងគ្រួសារក៏ដូចជាក្នុងសហគមន៍ផ្ញើរវាសនាទៅលើមន្ត្រីទាំងស្រុងមិនបានទេ! អ្នកទៅបោះឆ្នោតទោះជាបោះរបៀបណាក៏ដោយប្រយោជន៍នឹងបានដល់អ្នកពីព្រោះអ្នកនឹងក្លាយជាមនុស្សសំខាន់ ហើយមនុស្សសំខាន់តែងតែរកដំណោះស្រាយសម្រាប់ជីវិតនឹងសម្រាប់មិត្តភក្ត្រស្រួលជាងមនុស្សខ្វាត់ព្រាត់គ្មានមិត្ត ។ ពិសេសទៅទៀតនោះខ្មែរចេញទៅបោះឆ្នោតច្រើនពេលណានឹងផ្តល់ជ័យជំនះទៅឱ្យបេក្ខជនដែលខ្មែរភាគច្រើនចូលចិត្តជាមិនខានតែប្រសិនបើមិនបានបេក្ខជនដូចប្រាថ្នាក៏ដោយក្តីសម្លេងខ្មែរដ៏ច្រើនដែលបានចេញទៅបោះឆ្នោតនោះនឹងក្លាយទៅជាសម្ពាតដ៏មានឥទ្ធិពលលើមន្ត្រីផ្លូវការជាមិនខាន៕

**សូមលោកអ្នកកុំភ្លេចចេញទៅបោះឆ្នោត 1**

**ពិន សំខុន**



# គណបក្សសង្គ្រោះជាតិធ្វើសវនកម្មផ្ទៃក្នុងរដ្ឋសភា



បន្ទាប់ពីបានចូលកាន់មុខតំណែងលើកតំបូងក្នុងរដ្ឋសភាគណបក្សសង្គ្រោះជាតិបានលាតត្រដាងរឿងអំពើពុករលួយក្នុងរដ្ឋសភាបង្ករឡើងដោយមន្ត្រីមួយរូបដែលបានតែងតាំងក្រុមគ្រួសារសាច់ញាតិខ្លួនឯងឱ្យកាន់កាប់មុខតំណែងសំខាន់ៗក្នុងរដ្ឋសភាដែលបង្កឱ្យមានភាពងាយស្រួលក្នុងការប្រព្រឹត្តអំពើពុករលួយ និងបញ្ហាចំណាយគ្មានតម្លាភាពដែលធ្វើឱ្យបាត់បង់ថវិការជាតិនាំមកនូវការប្រព្រឹត្តិអំពើពុករលួយមានលក្ខណៈជាប្រព័ន្ធទ្រង់ទ្រាយធំ និងបណ្តាលឱ្យខូចឈ្មោះដល់ស្ថាប័ននិតិប្បញ្ញត្តិដែលមានតួនាទីតាមដានភាពមិនប្រក្រតីនៃស្ថាប័នរដ្ឋនានា។

បន្ទាប់ពីបានចូលកាន់មុខតំណែងលើកតំបូងក្នុងរដ្ឋសភាគណបក្សសង្គ្រោះជាតិបានលាតត្រដាងរឿងអំពើពុករលួយក្នុងរដ្ឋសភាបង្ករឡើងដោយមន្ត្រីមួយរូបដែលបានតែងតាំងក្រុមគ្រួសារសាច់ញាតិខ្លួនឯងឱ្យកាន់កាប់មុខតំណែងសំខាន់ៗក្នុងរដ្ឋសភាដែលបង្កឱ្យមានភាពងាយស្រួលក្នុងការប្រព្រឹត្តអំពើពុករលួយ និងបញ្ហាចំណាយគ្មានតម្លាភាពដែលធ្វើឱ្យបាត់បង់ថវិការជាតិនាំមកនូវការប្រព្រឹត្តិអំពើពុករលួយមានលក្ខណៈជាប្រព័ន្ធទ្រង់ទ្រាយធំ និងបណ្តាលឱ្យខូចឈ្មោះដល់ស្ថាប័ននិតិប្បញ្ញត្តិដែលមានតួនាទីតាមដានភាពមិនប្រក្រតីនៃស្ថាប័នរដ្ឋនានា។

លិខិតនេះធ្វើឡើងដោយលោកសុន ឆ័យ តំណាងរាស្ត្រគណបក្សសង្គ្រោះជាតិមណ្ឌលភ្នំពេញ និងជាអនុប្រធានគណកម្មការ សេដ្ឋកិច្ច ហិរញ្ញវត្ថុ ធនាគារ និងសវនកម្មនៃរដ្ឋសភា ចុះថ្ងៃទី២១ ខែតុលា ផ្ញើជូនលោកឡេង ប៉េងឡុង អគ្គលេខាធិការរដ្ឋសភាស្នើឱ្យផ្តល់ឯកសារពាក់ព័ន្ធនឹងបញ្ជីឈ្មោះបុគ្គលិកទាំងអស់នៃអគ្គលេខាធិការដ្ឋាននេះ រួមទាំងពន្យល់ពីការគ្រប់គ្រងបុគ្គលិក និងបញ្ហាគំរោងចំណាយគ្មានតម្លាភាព។

លោក សុន ឆ័យបានលើកឡើងថា តាមព័ត៌មានដែលលោកទទួលបានលោក មិត្ត ការ៉េន អគ្គលេខាធិការរងនៃរដ្ឋសភាដែលធ្លាប់មានតួនាទីជាអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុបានប្រើប្រាស់ឥទ្ធិពលរបស់ខ្លួនតែងតាំងក្រុមគ្រួសារខ្លួនជាច្រើននាក់ រួមមាន កូនបង្កើត កូនប្រសារ ប្អូនបង្កើត ប្អូនថ្លៃ និងក្មួយជាដើមឱ្យបម្រើការងារក្នុងរដ្ឋសភា រួមមានលោកហង្ស វិចិត្រ ត្រូវជាកូនប្រសាររបស់លោកកាន់តំណែងជាអគ្គនាយករដ្ឋបាល និងហិរញ្ញវត្ថុ។ លោក មិត្ត ទីមាន កូនប្រុសបង្កើតជាប្រធានសវនកម្មផ្ទៃក្នុង និងលោក រ៉េន សុវឌ្ឍនា ជាអនុប្រធាននាយកដ្ឋានហិរញ្ញវត្ថុ ក្រៅពីនេះលោកមិត្ត ការ៉េន បានតែងតាំងក្មួយ ប្អូនថ្លៃអតីតប្អូនថ្លៃ និងកូនប្រសារឱ្យកាន់មុខតំណែងសំខាន់ៗក្នុងរដ្ឋសភាផ្នែកគ្រប់គ្រងថវិការក្នុងស្ថាប័ននេះ។ ក្នុងលិខិតបានស្នើឱ្យអគ្គលេខាធិការដ្ឋាននៃរដ្ឋសភាចាត់វិធានការជាបន្ទាន់តាមរយៈការបញ្ឈប់តួនាទី ឬព្យួរតួនាទីក្នុងក្រុមគ្រួសារលោកមិត្ត ការ៉េន ដើម្បីឱ្យមានការស៊ើបអង្កេតឯករាជ្យមួយរកការពិតក្នុងការនាំយកជនដែលប្រព្រឹត្តបទល្មើសទៅផ្តន្ទាទោសតាមច្បាប់។

លោក សុន ឆ័យ បានមានប្រសាសន៍ក្នុងលិខិតនោះទៀតថា ដោយសារតែលោកបានពិនិត្យមើលលើគំរោងចំណាយរបស់រដ្ឋសភាសម្រាប់ឆ្នាំ២០១៥ ឃើញថាមានភាពមិនប្រក្រតី និងគ្មានតម្លាភាពព្រោះគម្រោងចំណាយបានកើនឡើងជាងឆ្នាំចាស់ចំនួន១០លានដុល្លា។ លោកបានបញ្ជាក់ថាដូចនេះវាប្រាដកជាមានបញ្ហាពាក់ព័ន្ធទៅនឹងបុគ្គលិកមួយចំណែក ហើយអាចថា មានបុគ្គលិកដែលមានតែឈ្មោះអត់មកធ្វើការចេះតែដាក់ឈ្មោះមកដើម្បីយកលុយ ហើយការដាក់ក្រុមគ្រួសារឱ្យធ្វើការជាលក្ខណៈប្រពន្ធ័អីជាដើម... ដូច្នេះហើយបានជា យើងទាមទារឱ្យមានវិធានការដើម្បីសម្អាតសភាឱ្យស្អាត។ បុគ្គលិកនៅក្នុងបញ្ជីផ្លូវការរដ្ឋសភាមានចំនួន១៣៥០នាក់ និងបុគ្គលិកបណ្តែតមានប្រមាណជិត៥០០នាក់។ តែបើតាមធាតុពិតបុគ្គលិកមានមិនដល់ប្រមាណជាងពាក់កណ្តាលផងទេបានមកធ្វើការ ចំណែកឯបុគ្គលិកផ្សេងទៀតសុទ្ធតែបុគ្គលិកដែលមានឈ្មោះក្នុងបញ្ជីខ្មោច ដែលត្រូវលោកមិត្តការ៉េននិងសាច់ញាតិបំប៉ោងដើម្បីបន្លំថវិការជាតិនេះ បើតាមការបញ្ជាក់ពីលោក សុន ឆ័យ។ ចំណែកឯលោក ឡេង ប៉េងឡុង អគ្គលេខាធិការរដ្ឋសភាបានថ្លែងថា លោកបានទទួលលិខិតនោះហើយប៉ុន្តែមិនទាន់អាចឆ្លើយតបបានទេ ដោយលោករង់ចាំការសម្រេចរបស់ថ្នាក់ដឹកនាំ និងគណកម្មការអចិន្ត្រៃយ៍រដ្ឋសភាជាមុនសិន។ លោកបានបញ្ជាក់ថា ខ្ញុំជាមន្ត្រីរដ្ឋបាលខ្ញុំធ្វើទៅតាមច្បាប់ខ្ញុំមានបញ្ជីបុគ្គលិកបានទេ រងការសម្រេចពីថ្នាក់ដឹកនាំហើយនឹងជម្រាបជូនឯកឧត្តម សុន ឆ័យ តាមក្រោយ។ រីឯអង្គភាពប្រឆាំងអំពើពុករលួយដែលដឹកនាំដោយលោក ឱម យ៉ិនទៀង ជាបធានមិនមានប្រតិកម្មអ្វីទាំងអស់ពាក់ព័ន្ធក្នុងរឿងនេះ៕




GREATER LOWELL
CHAMBER OF COMMERCE

131 Merrimack Street – Lowell MA
978-459-8154
www.greaterlowellchamber.org

A resource for your business or organization!
Networking Events
Seminars
Resources
TV & Radio Shows
And more!

សភាពាណិជ្ជកម្មនៅក្រុងឡូវែល គឺជាធនធានមួយសម្រាប់មុខរបរ ឬសម្រាប់អង្គការរបស់លោកអ្នក
ព្រឹត្តិការណ៍ទំនាក់ទំនង
សន្និសីទ
រកធនធាន
កម្មវិធីទូរទស្សន៍ និងវិទ្យុ
និងនៅមានច្រើនទៀត

នៅថ្ងៃទី ២៨ ខែតុលា ឆ្នាំ២០១៤ និងមានតាំងពិពណ៌ពាណិជ្ជកម្ម និងបង្ហាញផលិតផលនៅសណ្ឋាគារ រ៉េឌីសាន់ នៅឆែមហ្វត។
Save the Date: Business Expo & Showcase on October 28th at the Radisson Hotel & Suites in Chelmsford.




# ហ្វូរ និងដីរី បំរើទេសចរណ៏

**សៀមរាបអង្គរ :** ដីរីឈ្មោះ ទីទុំ គឺជាដីរីដែលមានអាយុ៣៥ឆ្នាំ ធ្វើការបំរើទេសចរណ៏៧ថ្ងៃក្នុងមួយអាទិត្យក្នុងចំណោមដីរី៦ដែលដឹកជញ្ជូនក្រុមទេសចរណ៏ទៅទស្សនាជុំវិញអង្គរធំ ។ ទីទុំ មានទម្ងន់ជាង២០០០គីឡូក្រាម បរិភោគអាហារ២០០គីឡូក្រាម និងផ្ទូតទឹក៤ដងក្នុងមួយថ្ងៃ ។

ទីទុំ បំរើការងារក្នុងក្របខណ្ឌអង្គភាពអប្សរាដោយពុំមានសញ្ញានើយហត់ ឬតវ៉ាអ្វីបន្តិចឡើយ ក៏ប៉ុន្តែគេអាចមិនសប្បាយចិត្តនៅពេលឃើញហ្វូររបស់គេមានទំនាក់ទំនងជាមួយនឹងនារីស្អាតណាមួយគេអាចនឹងកៀសបណ្ដេញនារីចេញឆ្ងាយ ឬក៏មិនស្ដាប់បញ្ជាហ្វូររបស់ខ្លួន ដោយមិនឱ្យឡើងជិះលើខ្លួនឡើយ ។



ចំណែកឯហ្វូរវិញ បំរើការងារដូចគ្នាក្នុងពេល៦ថ្ងៃក្នុងមួយអាទិត្យទៅណាមកណាតែងនៅជាប់នឹងទីទុំជានិច្ចលើកលែងតែថ្ងៃឈប់សម្រាកដែលមានហ្វូរផ្សេងមកជំនួស ។ ហ្វូរដីរី ខកខានមិនបានជួបភរិយាខ្លួនក្នុងរយៈពេល៦ថ្ងៃនោះ ដោយមិនចង់ឱ្យទីទុំប្រច័ណ្ឌ ។ ទីទុំយល់នូវប្រយោគដែលមនុស្សទាំងនិយាយគ្នាជុំវិញខ្លួន តែមិនអាចបញ្ចេញសំដីឆ្លើយឆ្លងវិញបានទេ មានតែបង្ហាញអាកប្បកិរិយារីករាយដូចជាទទួលបានដូងពីភ្ញៀវចាប់ដាក់ក្នុងមាត់ទំពារតែម្ដងអស់រលីង ឬក៏បង្ហាញការមិនពេញចិត្តដោយមិនស្ដាប់បញ្ជា ។ ទីទុំសប្បាយចិត្តណាស់ ដោយបានហ្វូររបស់ខ្លួននៅថៃទាំខ្លួនបានជាង១០ឆ្នាំមកហើយ ។

**ហ្វូរដីរី ថ្ងៃទី ០១ វិច្ឆិកា ២០១៤**



# ភាពជាប់គាំងនៃវត្តត្រៃរតនារាមនៅតែបន្តស្វែងរកដំណោះស្រាយ

មូលហេតុអ្វីទើបវត្តត្រៃរតនារាមនៅបន្តបិទទ្វារដដែល តើមានការសំរុះសំរួលដែរ ឬទេ? ការស្វែងរកដំណោះស្រាយទំនាស់ជាប់គាំងសាលាធម្មសភានៅវត្តត្រៃរតនារាមដែលរួមមានគណកម្មការវតតលើ និងវតតក្រោមបានលើកឡើងនូវសំណើរវៀង១ខ្លួនដើម្បីស្វែងរកការកែភាពនឹងឈានទៅរកភាពប្រក្រតីនៅដំណើរការវត្តត្រៃរតនារាម ប៉ុន្តែសំណើរទាំងនោះត្រូវបានភាគីម្ខាង១បដិសេធរៀង១ខ្លួននៅក្នុងចំណុចទី៤នៃសំណើររបស់គណកម្មការវតតក្រោមបានស្នើរថា ត្រូវកោះប្រជុំគណកម្មការវត្តលើ និងគណកម្មការវត្តក្រោមដើម្បីរៀបចំច្បាប់ឱ្យបានហ្មត់ចត់ជាមុនសិន មុនជ្រើសរើសគណកម្មការឯករាជ្យថ្មីបន្ទាប់ពីច្បាប់ត្រូវបានរៀបចំ ហើយទើបផ្សព្វផ្សាយជាសាធារណាឱ្យពុទ្ធិបរស័ទទាំងអស់គ្នាបោះឆ្នោតជ្រើសរើសបេក្ខជនគណកម្មការឯករាជ្យថ្មី ត្រង់ចំណុចនេះហើយដែលព្រឹទ្ធាចារ្យវត្តលើមិនឯកភាពតាមសំណើររបស់គណកម្មការវត្តក្រោមនោះទេ ដោយព្រឹទ្ធាចារ្យវត្តលើទាមទារជ្រើសរើសមនុស្សដោយខ្លួនឯងដើម្បីដំណើរការវត្តជាមុនសិន ទើបបង្កើតច្បាប់ជាក្រោយ។ នេះជាសំណើរដែលធ្វើឱ្យភាគីទាំងពីរមិនអាចចុះសម្រុងគ្នាឈានទៅរកចំណុចរួមមួយបានមតិរបស់ប្រធានគណកម្មការវត្តក្រោមលោក សាន បិន បានលើកឡើងថា ការស្នើររបស់ព្រឹទ្ធាចារ្យ វត្តលើមិនមានភាពយុត្តិធម៌ ត្រឹមត្រូវ។


លោក សាន បិន

អស់រយៈពេលជាង១៥ឆ្នាំមកហើយដែលវត្តត្រៃរតនារាមហៅថា វត្តចាស់បានបិទទ្វារមិនដំណើរការធ្វើឱ្យពុទ្ធបរិស័ទនៅរដ្ឋឡូវែលមានការទន្ទឹងរង់ចាំនិងខកចិត្តចំពោះការផ្អាកសកម្មភាពរបស់វត្តអស់ពេលយ៉ាងយូរ ហើយវត្តនេះក៏បានបែងចែកជាពីរចំណែក គឺវត្តលើ និងវត្តក្រោម។ ដើម្បីឱ្យសាធារណជនបានជ្រាបពីបញ្ហានេះ លោក ពិន សំខុន ចាងហ្វាងកាសែតខ្មែរផុសក៏បានធ្វើកិច្ចសម្ភាសន៍ជាមួយគណកម្មការវត្តដែលមានខ្លឹមសារដូចខាងក្រោម :

**លោក ពិន សំខុន : កិច្ចសម្ភាសន៍ថ្ងៃនេះខ្ញុំចង់ដឹងអំពីវត្តលើ និងវត្តក្រោម ឥឡូវបានបិទទៅហើយ តើមានវាសនាបើកវិញទេ?**

**លោក សាន បិនៈ** សូមអរគុណសូមជម្រាបជូនលោក ពិន សំខុន ដែលជាចាងហ្វាងកាសែតខ្មែផុសឱ្យបានជ្រាបថា ថ្ងៃទី៤ ខែកញ្ញាលោក សផែល បានទៅចរចាជាមួយតាតាទាំងបួននាក់ ប៉ុន្តែមិនមានការអនុញ្ញាតិពីគណកម្មការទេ គ្រាន់តែជជែកគ្នាពីនេះពីនោះសំណេះសំណាលគ្នាតាមទូរស័ព្ទ ហើយក៏បានប្រជុំគ្នាគាត់នៅថ្ងៃនេះដែរ ក្នុងអង្គប្រជុំនោះមានគ្នាចំនួន៦នាក់ នៅវត្តថ្មី ដោយបញ្ជូនរបាយការណ៏នៅថ្ងៃនោះយកមកឱ្យខ្ញុំមានសំណើរខ្លះដូចតទៅ :

**ទីមួយៈ** ត្រូវថែរក្សាការពារឈ្មោះវត្តនៅដដែល គឺវត្តត្រៃរតនារាម

**ទីពីរៈ** បង្កើតគណកម្មការថ្មីមួយកែរាជ្យដោយក្រុមស្មូមទាំងប្រាំ

**ទីបីៈ** ព្រះសង្ឃដែលគង់នៅក្នុងវត្តត្រៃរតនារាមអាចគ្រប់គ្រងឧបត្ថម្ភសាលាតាមសំណូមពរគណកម្មការកែរាជ្យ

**ទីបួន :** គណកម្មការទាំងពីរក្រោមលើត្រឡប់ទៅជំនុំពិគ្រោះគណកម្មការរៀង១ខ្លួនដោយស្ងាត់ស្ងៀម

**ទីប្រាំ :** គណកម្មការលើក្រោមទាំងពីរឯកភាពសុខចិត្តលាលែងរំសាយគណកម្មការរបស់ក្រុមដោយសុទិដ្ឋិនិយម

**ទីប្រាំមួយៈ** កំណត់កាលបរិចោទអង្គប្រជុំលើកក្រោយតាមសំណូមពរភាគីទាំងសងខាងអង្គប្រជុំដូចខ្ញុំបានរៀបរាប់ខាងលើរួចហើយ ហើយខ្ញុំលោក (សាន បិន) បានកោះប្រជុំ គណកម្មការវត្តក្រោមដោយបានលើកឡើងនូវសំណើរដូចតទៅនេះ:

**តទៅទំព័រទី ១៣**

សំណើរចំពោះព្រឹទ្ធាចារ្យទាំងបួន (វត្តលើ)


## សូមដាក់ពាក្យសុំចូលបញ្ជីរង់ចាំនៃកម្មវិធីជំនួយថ្លៃជួលផ្ទះនៃរដ្ឋម៉ាស្សាឈូសែត

**អ្នកដាក់ពាក្យ គឺត្រូវបានគេទទួលយកសំណុំឯកសាររហូតដល់ម៉ោង៥ល្ងាច ថ្ងៃទី៣ ខែវិច្ឆិកា ឆ្នាំ២០១៤**

សំណុំឯកសារទាំងឡាយ ដែលបានដាក់ទាន់ពេលវេលា គឺត្រូវបានគេដាក់បញ្ចូលទៅក្នុងធុងឆ្នោតមួយ ដើម្បីបញ្ជាក់ពីការដាក់ចូលក្នុងបញ្ជីរងចាំ។ រីឯថ្ងៃខែដាក់ពាក្យសុំ ក៏នឹងមិនមានអ្វីប៉ះពាល់ដល់ការដាក់ពាក្យចូលក្នុងបញ្ជីរងចាំនោះឡើយ។

**អ្នកដាក់ពាក្យសុំទាំងឡាយ ត្រូវតែមានកំរិតប្រាក់ចំណូលដូចតទៅៈ**

កំរិតទ្រព្យសម្បត្តិៈ 1.5 នៃប្រាក់ចំណូលប្រចាំឆ្នាំរបស់ក្រុមគ្រួសារ ឬ $15,000 មួយណាដែលច្រើនជាង ។

ប្រាក់ចំណូលប្រចាំឆ្នាំរបស់ក្រុមគ្រួសារត្រូវស្ថិតនៅក្រោមកំរិតបរិមាណដូចខាងក្រោមៈ

| Household Size | 1 | 2 | 3 | 4 | 5 |
|---|---|---|---|---|---|
| Lowell Area Maximum Income | $31,750 | $36,300 | $40,850 | $45,350 | $49,000 |
| Lawrence Area Maximum Income | $30,850 | $35,250 | $39,650 | $44,050 | $47,600 |
| Boston/North Shore Area Maximum Income | $32,950 | $37,650 | $42,350 | $47,050 | $50,850 |

**សំរាប់ពត៏មាន ឬដើម្បីដាក់ពាក្យសុំ សូមចូលមើលគេហទំព័រ www.commteam.org ឬការិយាល័យ Community Teamwork**

លិខិតចល័តបញ្ជាក់ MRVP នឹងផ្តល់ជាជំនួយថ្លៃផ្ទះ សំរាប់ក្រុមគ្រួសារ, បុគ្គល និងមនុស្សចាស់ទាំងឡាយណាដែលមានប្រាក់ចំណូលតិចតួច ដើម្បីជួលផ្ទះឯកជនផ្សេងៗ ។ គ្រួសារត្រូវបង់យ៉ាងហោចណាស់៣០% ប៉ុន្តែមិនច្រើនជាង៤០% នៃប្រាក់ចំណូលសំរាប់ថ្លៃជួយផ្ទះ ។ ប្រាក់ចំណូលគ្រួសារមិនត្រូវមានច្រើនលើស៥០% ឡើយ។

COMM UNITY TEAM WORK

**មានការសម្រួលសមរម្យ និងជំនួយផ្នែកភាសាផងដែរ បើសិនជាមានការស្នើសុំ ។**

Community Teamwork, Inc. | 155 Merrimack Street, Lowell, MA 01852 | 978-654-5610

EQUAL HOUSING OPPORTUNITY

## តមកពីទំព័រទី ១២ ភាពជាប់គាំងនៃវត្តត្រៃរតនារាម...

យោងតាមរបាយការណ៍ការស្វែងរកសមាទិដ្ឋិក្នុងសង្គម ចុះថ្ងៃទី៤ ខែកញ្ញា ឆ្នាំ២០១៤

គោលបំណងដំណោះស្រាយសាលាធម្មសភាវត្តត្រៃរតនារាមដែលជាប់គាំង

គណកម្មការយើងខ្ញុំបានសំរេចជូនដូចខាងក្រោម

**ទីមួយៈ** ស្នើរសុំប្តូរពាក្យស្នូម ហៅថា ព្រឹទ្ធាចារ្យវិញ

**ទីពីរៈ** សូមពន្យល់នូវចំណុចទីបីឱ្យបានលំអិត

**ទីបីៈ** សូមបន្ថែមព្រឹទ្ធាចារ្យ១នាក់ទៀត ឱ្យបានទៅជាប្រាំ

**ទីបួនៈ** មុនជ្រើសរើសគណកម្មការឯករាជ្យថ្មីត្រូវរៀបចំច្បាប់បោះឆ្នោតជាមុនខ្ញុំយល់ស្របការរៀបចំគណកម្មការជាថ្មី ប៉ុន្តែត្រូវរៀបចំបោះឆ្នោតដោយមិនត្រូវនិយាយដោយមាត់ទទេ ដូចនេះខ្ញុំស្នើរសុំឱ្យមានការរៀបចំច្បាប់ជាមុន ។

**ទីប្រាំៈ**សំណើរសុំឱ្យមានការផ្សព្វផ្សាយជាសាធារណដើម្បីជ្រើសរើសបេក្ខជនគណកម្មការថ្មី ដោយផ្សព្វផ្សាយ តាមវិទ្យុ ទូរទស្សន៍ កាសែត ឬពិធីបុណ្យទានក្តី ដើម្បីរកអ្នកស្ម័គ្រចិត្តរៀបចំវត្តក្នុងការឈរឈ្មោះជាគណកម្មការមកដាក់ពាក្យ តាមសំណូមពរតាមការឯកភាពគ្នា ដើម្បីបញ្ចប់រឿង




វត្តក្រោមដែលមានលោក សាន ប៊ិន ជាប្រធាន និងព្រះតេជគុណ សែម សារិន ជាចៅអធិការ

**ទីប្រាំមួយៈ** សូមឱ្យមានការប្រជុំជាសាធារណៈ ដើម្បីបោះឆ្នោតជ្រើសរើសគណកម្មការថ្មី ពេលណាដែលធ្វើច្បាប់ថ្មី ហើយរកបានបេក្ខជនសមរម្យ ហើយយើងត្រូវធ្វើការផ្សព្វផ្សាយជាសាធារណៈ ត្រូវអញ្ជើញពុទ្ធបរិស័ទឱ្យមកបោះឆ្នោតជ្រើសរើសគណកម្មការថ្មីមកកាន់កាប់វត្តនេះ

**ទីប្រាំពីរៈ** គណកម្មការវត្តខាងលើក្រោមយល់ស្របតាមសំណើរនូវចំណុចទី៥ខាងលើ គណកម្មការវត្តលើវត្តក្រោមចាស់ត្រូវរំសាយដោយស្វ័យប្រវត្តិនៅពេលតែងតាំងគណកម្មការកែរាជ្យថ្មី ។

**ទីប្រាំបីៈ** នៅពេលដែលចូលរួមធ្វើច្បាប់បោះឆ្នោតគណកម្មការចាស់ទាំងវត្តលើវត្តក្រោមសុំចូលរួមធ្វើច្បាប់នេះផងដែរ ។ លោក សាន ប៊ិន បានបន្តថា ត្រូវចូលរួមសហការគ្នាធ្វើដើម្បីកសាងវត្តឱ្យបានល្អឡើង ប៉ុន្តែតាមគំនិតរបស់គាត់ព្រឹទ្ធាចារ្យវត្តលើកាលពីមុនបានប្រជុំទាំងបីនាក់ មានខ្ញុំ ជា តែម និង សុខ អ៊ឹម គំនិតគាត់ចង់ធ្វើវត្តជាមុន ទើបរើស គណកម្មការជាក្រោយខ្ញុំថាវាអត់ត្រឹមត្រូវទេ ត្រូវរើសគណកម្មការមុនទុកឱ្យគណកម្មការថ្មីឯករាជ្យជាអ្នករៀបចំវត្ត រៀបចំច្បាប់ លក្ខន្តិកៈរបស់វត្តអាចយកច្បាប់ចាស់មកមើល បើល្អទុកទៅ បើមិនល្អត្រូវដកចេញ គណកម្មការថ្មី មានសិទ្ធិគ្រប់គ្រាន់នឹងរៀបចំលក្ខន្តិកៈថ្មីរបស់វត្ត។

តទៅទំព័រទី ២៨

**បើចង់បានសៀវភៅទាំងនេះ សូមទាក់ទងទៅ សាគូ សាមុត 06 23 10 05 08 ប្រទេសបារាំង**






# តមកពីទំព័រទី ៤ ដំណើរពីអាមេរិកទៅអាស៊ី

សញ្ញានៃការលំបាកក្នុងការធ្វើដំណើរឆ្លងប្រទេសដោយខ្វះការទទួលភ្ញៀវឱ្យបានគ្រប់គ្រាន់ ។ តែយ៉ាងមេចក៏ដោយអីវ៉ាន់ក្នុងយន្តហោះជើងមុនក៏បានចេញចោលយើងផុតទៅហើយទៀតដែរ ។

ម៉ោង១២អាធ្រាតនៃថ្ងៃ១៣ យើងបានមកដល់បាងកកដូចប្រាថ្នាបន្ទាប់ពីជិះយន្តហោះកាថេថ្មីមួយទៀតតែតូចជាងមុនយើងអង្គុយកន្លែងបែកគ្នាអស់រយៈពេល២ម៉ោងកន្លះ ទើបមកដល់ចំណតយន្តហោះអន្តរជាតិថ្មីស្រឡាងនៃបាងកកដែលមានមនុស្សទទួលភ្ញៀវចេះរាកទាក់រីករាយគ្រងបានប្តូរជាស្រស់បស់ដោយភាពទទួលភ្ញៀវស្នាមញញឹមខុសពីអតីតកាលដែលប៉ូលីសអន្តោប្រវេសន៍ថៃមុខដូចយក្ខពេលឆ្លងកាត់ពួកគេម្តងៗអ្នកដំណើររងចាំបោះត្រា"វីសារ"ដូចមកសុំទានអ៊ីចឹង ។ ទីបញ្ចប់យើងរកឥវ៉ាន់ដែលមកជើងមុនឃើញទាំងអស់ ហើយក៏រកអ្នកជូនដំណើរដែលមិនដែលឃើញគ្នាពីមុនមកឃើញទៀត ។

នូតបាននាំយើងទាំង៣មកដល់សណ្ឋាគារវិនស័រស្វ៊ីត Winsor Suite ប្រកបដោយសុវត្ថិភាពថៃមទាំងទៅទិញម្ហូបខ្ចប់ឱ្យយើងស្រស់ស្រូបកុំសង្វេកនឹងភាពរីករាយនេះទៅវិញដោយសារមើលឃើញពីក្រោយឆាកល្ខោននេះនូវសកម្មភាពពេស្យាចារ្យនឹងភាពខ្វះការងារត្រឹមត្រូវរបស់ស្ត្រីទើបបានជាយើងសង្វេកទៅវិញគួរឱ្យស្តាយ ។ យប់នេះយើងស្រស់ស្រូបបន្តិចបន្តួចហើយសំអាតខ្លួនរួចផ្តួលខ្លួនព្រួសលើគ្រែពូកដ៏រឹងបន្ទប់នៅមានក្លិនផ្សូរតិចៗដែលសូបិននៅមានចាប់អារម្មណ៍នៅឡើយចំណែកខ្ញុំបានលក់លង់យ៉ាងជ្រៅទៅហើយ ។

ព្រឹកឡើងយើងដាស់គ្នានៅម៉ោង១០ព្រឹក កុំឱ្យដេកយូរពេកវាអាចនឹងខូចដំណោកនារាត្រីធ្វើឱ្យយើងមានកម្លាំងនឹងបន្តរដំណើរទោះជាហត់នឿយណាស់ក៏ដោយជាពិសេសប៊ុណ្ណារ៉ូនៅតែបន្តទាមទារជួយរុញឥវ៉ាន់ដ៏ធ្ងន់ឱ្យយើងដោយទារថា I'll do it ! I'll do it !

## ២យប់៣ថ្ងៃនៅបាងកក

ខានមកកាន់ប្រទេសថៃជាង១០ឆ្នាំទេសភាពមិនផ្លាស់ប្តូរប៉ុន្មានទេ តែទិដ្ឋភាពនៃការគ្រប់ឱ្យឃ្លានពីព្រោះពោះកាន់តែកូររៀងៗខ្លួនហើយ ប៉ុន្តែ ប៊ុណ្ណារ៉ូ បានដេកលក់យ៉ាងស្កប់ស្កល់ទៅហើយដែរ...រីឯសកម្មភាពរាត្រីនឹងក្នុងទីងងឹតនាជុំវិញសណ្ឋាគារនឹងផ្លូវស៊ូគុមវិជ នាវេលាម៉ោង២អាធ្រាតមានភាពគគ្រឹកគគ្រេងគួរឱ្យភ្ញាក់ផ្អើលស្រីស្លៀកសំពត់អាវស្តើងខ្លីដើរប្រកៀកគ្នាត្រសងទាំងគូរទាំងក្រុមយ៉ាងរីករាយតែយើងបែរជាបន្ទាប់តែទម្រាំយើងចេញរួចម៉ោង១២ថ្ងៃត្រង់ទៅហើយ យើងក៏រម្រេចហូបអាហារថ្ងៃត្រង់នៅក្បែរៗសណ្ឋាគារដែលទិដ្ឋភាពរាត្រីថ្ងៃសៅរ៍មុននេះបន្តិចបានរលាយស្ងប់ស្ងាត់អស់រលីងដូចស្រមៃមាននៅសល់តែសកម្មភាពទទួលភ្ញៀវទេសចរតែប៉ុណ្ណោះ ។ សូបិននឹងប៊ុណ្ណារ៉ូមិនដែលមកស្គាល់ប្រទេសថៃទេ ជាពិសេស សូបិន បានបែកចេញពីវៀតណាមទៅរស់នៅស.រ.អា.ចំនួន ១៥ឆ្នាំហើយ មិនមានសល់អនុស្សាវរីយ៍នៃជីវភាពរស់នៅជនជាតិអាស៊ីច្រើនទេ ម្លោះហើយមាន

តទៅទំព័រទី ១៥



ព្រលានយន្តហោះប្រទេសថៃ


រីករាយពេលមកដល់ប្រទេសថៃ


ព្រះបរមរាជវាំងប្រទេសថៃ



១-ចេញដំណើរពីព្រលានយន្តហោះបស់ស្តុន
២-ប្តូរយន្តហោះនៅឈីកាហ្គោ
៣-ចុះសម្រាក៣ម៉ោងនៅហុងកុង បន្តដំណើរទៅបាងកក
៤-មកដល់បាងកកសម្រាក៣ថ្ងៃបន្តដំណើរទៅភ្នំពេញ
៥-មកដល់ភ្នំពេញ

## តមកពីទំព័រទី ១៤ ដំណើរពីអាមេរិកទៅអាស៊ី

ការខ្លាចនឹងផ្សងព្រេងជាមួយម្ហូបតាមផ្លូវណាស់ តែខ្ញុំបានពន្យល់ថា គឺម្ហូបនៅតាមថ្នល់នោះហើយ ដែលជាអាហារពិតប្រាកដនៃអ្នកដែលរស់នៅទីនេះតែចុងបញ្ចប់យើងសម្រាច់ហូបភីហ្សា Pizza នាហាងជាប់គ្នានោះ ដើម្បីបំពេញចិត្ត ប៉ុណ្ណារ៉ូ ដែលបានខំប្រឹងរក្សាខ្លួនជាក្មេងល្អ Good boy តាំងតែពីពេលចេញដំណើរមក។ យើងបានបញ្ជាភីហ្សាដែល ប៉ុណ្ណារ៉ូ ចង្អុលក្នុងរូប គឺ ប៊្លូឈីស Blue Cheese តែគេនិយាយថា ចង់ហូប ប៉ាប៉ារ៉ូនីភា parroni តែដល់យកម្ហូបមកគេហូបមិនបានដោយ ប៊្លូឈីស វាធំក្លិនស្អុយបន្តិចលើកនេះយើងបញ្ជាឱ្យយកប៉ាប៉ារ៉ូនីវិញម្តងបន្តិចមកយើងបានទទួលតែចានទទេ២មកដោយមិនដឹងជាហេតុអ្វី...អស់សង្ឃឹមថា និយាយគ្នាស្តាប់បាន ប៉ុណ្ណារ៉ូ ក៏ហូបតែនំប៉ុងគ្រៀម១ដែលនៅជុំវិញភីហ្សា ហើយក៏ទាចេញទៅរកហូបអ្វីផ្សេងវិញម្តង ។ ចុងបញ្ចប់យើងត្រឡប់មករកម្ហូបនៅសណ្ឋាគារដដែលដោយបញ្ជាម្ហូបកំឡុងនឹងត្រីចៀន Fish & French frite ឱ្យកូនទើបរួចខ្លួនឯយើងចាស់ៗស្រស់ស្រូបតែបន្តិចក៏ឆ្អែតទៅហើយ ។

រសៀលនេះយើងចង់ទៅឃើញផ្សារបណ្តែតទឹកដ៏ល្បីល្បាញនៅថៃនូតបាននិយាយប្រាប់យើងថា ផ្សារទឹកមិនមានទេ នៅពេលល្ងាចតែនៅមានផ្សារទឹកមួយទៀតដែលខ្ញុំស្គាល់គេបើកពេលល្ងាច ។ ទៅទីនោះ យើងជិះឡាន១ម៉ោងកន្លះទៅកាន់ខេត្តរាជ្ជសីមាទើបដល់ ។ ភ្លៀងធំបានបង្អុរខ្មោក១កាត់ដំណើរបស់យើងនៅពេលទៅដល់យប់ក៏មកដល់ដែរ តែមនុស្សម្នានៅច្រើនណែនណាន់តាន់តាប់នៅឡើយរថយន្តរាប់រយពាន់រកកន្លែងសំចតស្ទើរមិនបានយើងត្រូវទិញឆ័ត្រ២នឹងអាវភ្លៀងសម្រាប់ ប៉ុណ្ណារ៉ូ នៅពេលត្រូវដើរពីកន្លែងចតឡានទៅកាន់ផ្សារទឹកប៉ផ្អិចប៉ផ្អាចពេញផ្លូវ ប៉ុណ្ណារ៉ូ រអ៊ូថា ខ្ញុំឥតចង់ដើរកាត់ផុកទេក្រខ្វក់ណាស់ I don’twant to walk in the mud ! Ewe ! ដើរកាត់ផ្សារផង រអ៊ូផង ភ្លៀងនៅតែស្រក់មនុស្សនៅតែណែនតែម្តងបន្តិចទទួលថានេះជាជីវិតអ្នកស្រុកនេះគេរស់នៅយ៉ាងដូចនេះហើយបន្តិចមកក៏ដើរដល់អូរដ៏ចង្អៀតមួយដែលទូកអ្នកលក់ដូរម្ហូប ឬផ្លែឈើ ឬចាំដឹកអ្នកដំណើរនៅពពាក់ពពូនគ្នាតាមដងអូរជាភាពអស្ចារ្យមួយដែលមិនដែលប្រទះ។ នៅតាមផ្លូវទៅដងអូរនៃតំបន់អំផាវ៉ាផ្សារអណ្តែតទឹកមានម្ហូបចំណីជ្រក់មាំុនុំនែក កាពិ យីហ៊ុំអាំងគ្រប់ប្រភេទដាក់លក់ជាស្នាដៃធ្វើម្ហូបប្លែកៗគ្នាចង់ស្រក់ទឹកមាត់។ ក្លិនឈ្ងុយលាយនឹងផ្សែងសាច់អាំងនានាដឹងថាប្រាកដជាឆ្ងាញ់ណាស់ តែ ប៉ុណ្ណារ៉ូ វាដើរខ្ទប់ច្រមុះឧទ្ទានថា Ew ! Stinky !ស្អុយណាស់ៗ ធ្វើឱ្យយើងទប់សំណើចមិនបានសំណាងដែរ ដែលមិនមាននរណាស្តាប់គេបាន។ យើងបានម៉ៅកាណូតទូកធំស្អាតមួយជិះតែដល់ពេលឡើងម្ចាស់ទូកចង្អុលទុកតូចកញ្ចាស់មួយនៅបាំងពីក្រោយអោយយើងទៅជិះទូកនោះវិញគេថាទុកធំនេះឥតចេញទៅទេលុយចេញទៅបាត់ហើយគ្មានជម្រើសក៏សុខចិត្តយកទូកនោះទៅ។ យើងបានប្រទះអូរជាដៃទន្លេដ៏មានប្រយោជន៏ដោយសារកាណូតនាំភ្ញៀវទៅបំពេញភាជនីយដ្ឋានដែលនៅតាមដងទន្លេនឹងដងអូរអ្នកស្រែចំការអ្នករកស៊ីតូចតាចអាចបង្កើតមុខរបរមួយបានជាមួយនឹងអតិថិជនស្រែកឃ្លានមុខម្ហូបថ្មីៗ ឬក៏អាចបំរើតុលាងចានជញ្ជូនតវ៉ានធ្វើឱ្យមនុស្សជាច្រើនមានការធ្វើដោយមិនបាច់ទៅសុំទាន ដូច្នេះពលរដ្ឋបង្កើតការងាររាប់ពាន់ម៉ឺនចិញ្ចឹមខ្លួនដោយខ្លួនឯងបានយ៉ាងប្រសើរ ។ ភ្លៀងរាំងមេឃបានស្រឡះមកវិញតែយប់ក៏កាន់តែចុលមកជ្រៅយើងរៀបខ្លួនត្រឡប់មកបាងកកវិញ ទាំងមិនទាន់ហូបអាហារល្ងាចនៅឡើយដូច្នេះចាំហូបពេលមកដល់បាងកកសិន។ យើងបានចូលទៅភោជនីយដ្ឋានកណ្តាលវាលមួយដែលប្រជុំដោយអ្នកជំនាញធ្វើម្ហូបថៃសម្រាប់ពលរដ្ឋធម្មតាខ្ញុំបារម្ភតែ សូបិន មិនអាចហូបអាហារទាំងនោះបានដោយសុខភាពមិនមាំទាំ យើងបានហៅម្ហូបប្រជាប្រិយ៣-៤ មុខមានសម្លរម្ជូរ តុំយ៉ាំត្រីអាំង ឆាបន្លែ ជាមួយបាយលីង

**តទៅលេខក្រោយ**


ផ្លូវស្ទុតមរឹងដ៏ចង្អៀតនៃបាងកក







**KhmerPost USA, LLC**

**សារពត៌មានខ្មែរផុសសហរដ្ឋអាមេរិក**

អាស័យដ្ឋាន 45 Merrimack St. Suite 218A. Lowell, MA 01852

លេខទូរស័ព្ទ Phone: 978 677-7163 | Fax: (978) 677-7092

អ៊ីម៉ែល info@khmerpost.us

អានកាសែតនៅគេហទំព័រ www.khmerpost.us

តាមដានយើងនៅទំព័រហ្វេសប៊ុក Like us at: www.facebook.com/KhmerPostUSA

**ផ្សាយពាណិជ្ជកម្ម Advertising**

អគ្គនាយកទីផ្សារ និងគ្រប់គ្រង សុបិន្ត ពិន Soben Pin, *Managing Partner*

លេខទូរស័ព្ទ 978 - 656 - 8141 (Mobile) 978 677-7163 (Office)

អ៊ីម៉ែលsobenpin@khmerpost.us

**អ្នកនិពន្ធ Editorials**

និពន្ធនាយក ពិន សំខុន Roger Samkhon Pin, *Publisher & Editor-in-Chief*

(978) 942 - 1641 | rogerpin@khmerpost.us

អ្នកនិពន្ធកិត្តិយស **Contributed Writers:**

Kim Phien, Richard Howe,Jr.

**ច្នៃសោភ័ណភាពកាសែត Design Artist**

Heng Chhunleng

**ជំនួយការរដ្ឋបាល** Intern

Moniphal Bing

KhmerPost USA, LLC is an independent newspaper that aims to facilitate mass communication among the Cambodian communities, their neighboring communities, and families. We aim to address local community, and national news; and give an insight into Cambodian & global news. We also strive to bridge the language and cultural gaps and reduce social isolation by publishing in Khmer & English. It published twice a month in Massachusetts serving Greater Lowell, Lynn, Revere, MA, Providence, RI, CT, NY, NJ, and Philadelphia, PA.

Mail subscription is available within the U.S. & Canada at 100.00 or 120 Euros in Europe per year.

The KhmerPost USA has full authorization from Bernard Krisher, the publisher of the Cambodia Daily to reproduce all the articles that are produced by the Cambodia Daily free of charge effective date: 6/19/2009

ឌឹ ខេមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសម្រួលពីភាសាអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ខេមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ សៅរ៍ ទី២០ ខែតុលា ឆ្នាំ២០១៤

# បណ្តាញព្រះសង្ឃស្នើឱ្យរដ្ឋាភិបាលពិនិត្យបញ្ហាគាបសង្កត់ក្នុងវត្ត២នៅបាត់ដំបង

**ដោយៈ បាន វិទ្យាថ្ងៃអង្គារ ទី២១ តុលា ២០១៤**

បណ្តាញព្រះសង្ឃឯករាជ្យស្នើរាជរដ្ឋាភិបាលដោះស្រាយបញ្ហានៅក្នុងវត្តដំណាក់បេង និងអន្តរាគមន៍បញ្ឈប់ការរំលោភបំពានមកលើវត្តភ្នំខ្ពស់ដែលត្រូវគេអះអាងថា ចៅអធិការវត្តត្រូវបានបញ្ឈប់ព្រោះរឿងនយោបាយ ។

ស្ថាបនិកបណ្តាញព្រះសង្ឃឯករាជ្យព្រះតេជគុណ ប៊ុត ប៊ុនតិញ មានសង្ឃដីកានៅក្នុងសន្និសីទសារព័ត៌មាននៅភោជនីយដ្ឋានបៃតង នារសៀលថ្ងៃអង្គារនេះថា ទង្វើរបស់មន្ត្រីសង្ឃក្នុងខេត្តបាត់ដំបងដែលព្រះតេជគុណអះអាងថា បានរួមដៃជាមួយមន្ទីរធម្មការ និងសាសនាជាបញ្ហាខុសឆ្គង។ ព្រះតេជគុណបន្តថា ព្រះអង្គ ភួង មុន្នី ដែលជាលេខារបស់មេគុណខេត្ត និងមានតួនាទីថ្មីក្នុងការចាត់ចែងព្រះសង្ឃក្នុងខេត្តបាត់ដំបងបានទទួលសំណូកពីព្រះចៅអធិការវត្តដំណាក់បេង គឺព្រះតេជគុណ សន ពៅ ជារៀងរាល់ខែ ចំពោះបញ្ហាពាក់ព័ន្ធព្រះចៅអិការវត្តអង្គនេះ ធ្វើជំនួញនៅក្នុងវត្តលើវត្ថុដែលពុទ្ធបរិស័ទប្រគេន និងធ្វើការបណ្តេញចេញភិក្ខុ ពត ជីវ័ន្ត ដោយគ្មានមូលហេតុសមហេតុផលឡើយ ។

VOD មិនអាចទាក់ទងព្រះតេជគុណព្រះអង្គ ភួង មុន្នី ជុំវិញបញ្ហានេះបាននៅឡើយទេ ដោយទូរសព្ទចូលតែពុំមានអ្នកទទួល ។

ព្រះតេជគុណ ប៊ុត ប៊ុនតិញ មានសង្ឃដីកាឱ្យដឹងទៀតថា ព្រះចៅអធិការវត្តភ្នំខ្ពស់ ព្រះតេជគុណ ឃឹម សំអឿន ត្រូវបានគេដកតំណែងចេញដោយព្រះអង្គធ្វើសកម្មភាពជួយសង្គមដូចជាការជីកស្រះ និងជួយប្រជាពលរដ្ឋក្នុងអំឡុងពេលដែលជួបបញ្ហាទឹកជំនន់ ប៉ុន្តែមន្ត្រីគណបក្សប្រជាជនក្រុមប្រឹក្សាខេត្ត និងមន្ត្រីសង្ឃខេត្តបែរជាព្រមានព្រះអង្គឱ្យឈប់ធ្វើសកម្មភាពចែកអំណោយ និងជីកស្រះ បើមិនអញ្ចឹងទេនឹងត្រូវដកតំណែងចេញ។

តទៅទំព័រទី ២១

# Web monks asked the government to examine issues suppressed in Wat 2 in Battambang

**By: Tuesday, October 21, 2014**

Network of independent monks asked the government to solve problems in the present stage cup and intervene to stop violations of the Wat was claimed pagoda was stopped because of politics.

Independent Network founder monk Loun But buy a monk in bronze press conference on the Green restaurant, Tuesday afternoon that the actions of officials Priest In Battambang, Monk claims that have joined hands with the Department of Religious Cults and error. Monk said he bouquet Mony, the provincial secretary of the coefficient and a new role in managing monk in Battambang received bribes from the pagoda cup stage is the youngest Venerable every month for issues involving council of M. In this business in a Buddhist pagoda on objects Offered The eviction Ven physical living without reasonable cause.

VOD can contact Loun bouquet Mony around this issue yet, tap phones, but none of the recipients.

Buntenh Bun buy monk said the high mountain monk monastery monk Khim Sam Ouen was stripped by social activities such as digging ponds and help residents during floods but officials CPP provincial council and provincial officials priest turned warned him to stop working Gifts and digging ponds, if not then it will be removed.

Independent Network chief monk Venerable day any rights, said he is immoral priests and Cult province with the authorities suppressed to deal with it, so he asked the Prime Minister to consider the deal. Monk said he could stop taking the authorities to suppress by priests local authority officials to Jonathan to stop the abuse monks anymore .

Active network of independent monks **Continued to page 21**

# តុលាការចោទប្រកាន់បុរសបីនាក់ពីបទសម្លាប់អ្នកកាសែតម្នាក់

**ដោយ សាំង សុផន្នារិទ្ធ AND សៃម៉ុន ហេនដឺរសិន | OCTOBER 15, 2014**

មន្ត្រីតុលាការម្នាក់បានលើកឡើងថា កាលពីម្សិលមិញសាលាដំបូងខេត្តក្រចេះបានចោទប្រកាន់បុរសបីនាក់ដែលត្រូវបានចាប់ខ្លួនពីបទសម្លាប់លោក តាំង ទ្រី អាយុ៤៩ឆ្នាំ ជាអ្នកកាសែតម្នាក់ក្នុងស្រុកស្នួល កាលពីព្រឹកថ្ងៃអាទិត្យ ហើយបានបញ្ជូនទៅពន្ធនាគារខេត្តដើម្បីរង់ចាំការកាត់ក្តី។

ការសម្លាប់អ្នកកាសែតនេះបានបង្កឱ្យមានការថ្កោលទោសយ៉ាងខ្លាំង ពីព្រោះជនសង្ស័យទាំងអស់មកពីកងកម្លាំងសន្តិសុខក្នុងប្រទេសកម្ពុជា។ អង្គការសិទ្ធិមនុស្សបានអំពាវនាវឱ្យមានស៊ើបអង្កេតឱ្យបានល្អិតល្អន់ និងការកាត់ក្តីដោយមិនលម្អៀងដើម្បីកែប្រែវប្បធម៌និទណ្ឌភាពចំពោះបទឧក្រិដ្ឋដ៏ឃោរឃៅលើអ្នកដែលស៊ើបអង្កេតការកាប់ឈើខុសច្បាប់។

លោក ទី សុវិនថាល់ ព្រះរាជអាជ្ញាអមសាលាដំបូងខេត្តបានមានប្រសាសន៍ថា "យើងបានចោទប្រកាន់ពួកគេពីបទមនុស្សឃាត។ នៅទូទាំងប្រទេសប្រជាពលរដ្ឋបានដឹងពីសកម្មភាពរបស់ពួកគេ ហើយពួកគេទាំងអស់ប្រឈមនឹងការជាប់ពន្ធនាគារយ៉ាងតិច១០ឆ្នាំ"។

ចុងចោទទាំងនោះគឺឈ្មោះ បែន ហៀង អាយុ៣១ឆ្នាំ នាយប៉ុស្តិ៍ឃុំស្រែឈូកក្នុងស្រុកកែវសីមា ខេត្តមណ្ឌលគិរី លោក ឃឹម ភក្តី អាយុ២៧ឆ្នាំ មន្ត្រីកងរាជអាវុធហត្ថរាជធានីភ្នំពេញ និងជាអតីតអនុរក្សព្រៃឈើក្នុងស្រុកកែវសីមា និងខ្មាន់កាំភ្លើងឈ្មោះ ឡា ណារ៉ុង អាយុ៣២ឆ្នាំ អតីតទាហានកងយោធពលខេមរភូមិន្ទនៅក្នុងខេត្តមណ្ឌលគិរី។

អ្នកទាំងបីនាក់នេះបានសារភាពចំពោះបទឧក្រិដ្ឋនេះនៅសន្និសីទកាសែតមួយកាលពីថ្ងៃច័ន្ទ ដោយអះអាងថា ពួកគេបានបាញ់ប្រហារបន្ទាប់ពីការផឹកស៊ីនៅពេលយប់។ ពួកគេបាននិយាយថា អ្នកយកព័ត៌មានរូបនេះបានគំរាមបង្ហាញសកម្មភាពកាប់ឈើខុសច្បាប់របស់ពួកគេនៅព្រឹកថ្ងៃនោះ នៅពេលពួកគេមិនព្រមឱ្យទូកគាត់ខ្ចី។

លោក សុវិនថាល់ បានមានប្រសាសន៍ថា "ប្រសិនបើពួកគេខឹងនឹងអ្នកយកព័ត៌មាននោះចំពោះការព្យាយាមជំរិតទារប្រាក់ ឬអ្វីផ្សេងពីពួកគេនោះ ពួកគេគួរដាក់ពាក្យបណ្តឹងទៅតុលាការ

តទៅទំព័រទី ២១

# The court accused the three men accused of killing journalist

**GASOLINE FUEL AND BRONZE VESSELS MONTANA HEINRICH SANDERS | OCTOBER 15, 2014**

A court official said that yesterday Kratie provincial court charged three men who were arrested on charges Killed Try, 49, a journalist in the District last Sunday morning and sent to prison pending trial .

The killing of journalists has sparked condemnation greatly because all the suspects are from the country's security forces Cambodia. Human rights organizations have called for a probe to be scrutinized and impartial trial, to change the culture of impunity For Desperate crimes you investigate illegal logging.

He said prosecutors Provincial Court, said, "We accused them of murder. Across the country people were aware of their activities, and they all face a prison term of at least 10 years. "

Additional defendants are named Heang, 31, chief of the commune lotus fields in Keo Seima district Mondulkiri Khim loyal, 27 military police officers Phnom Penh and a former forest ranger Seymar and gunmen Narong, 32, a former Royal Cambodian Armed Forces soldiers in Mondulkiri.

The three confessed to the crime at a press conference last Monday, claiming that they were shooting After a drink at night. They said that reporters had threatened their illegal logging in the morning, when they They refused to lend his boat.

He said, "If they're angry with reporters for trying to extort money or other things , they should file a complaint with the court, but they shot him violently back. "

He concluded that the investigating judge will spend at least three months to try to determine the exact cause of the shooting this.

But there is concern that the arrest and the charges so quickly means that the authorities are protecting military officials Senior signed in the District, which is rumored Aramaic behind the illegal logging in the area.

Mrs. Laura King (Laura King) communications manager at the Cambodian Center for Independent Media, said that was investigated thoroughly to find out the cause of the killings and to ensure that those involved be convicted.

She said, "If we have a truly independent court, we can get real justice for the murder and intimidate independent journalists from the start so since the democratic elections in 1993. " **Sarun**

ឌឹ ឃែមបូឌា ដេលី The Cambodia Daily

ដំណឹងប្រែសំរួលពីកាសារអង់គ្លេស អត្ថបទដកស្រង់ និងទទួលការអនុញ្ញាតឱ្យធ្វើការចុះផ្សាយពី ឌឹ ឃែមបូឌា ដេលី ច្បាប់ចេញផ្សាយថ្ងៃ សៅរ៍ ទី២០ ខែតុលា ឆ្នាំ២០១៤

# គណបក្សសង្គ្រោះជាតិលើកឡើងថា សកម្មជនមានផែនការបំបែកសំឡេងរបស់ខ្លួន

**ដោយៈ អេឡិក វិល្លឹមមីនស៍** | **OCTOBER 20, 2014**

ការឈ្លោះប្រកែកគ្នារវាងកូនស្រីច្បងរបស់



កញ្ញា កឹម មនោវិទ្យា



កញ្ញា ធី សុវណ្ណថា



លោក កែម ឡី

លោក កឹម សុខា អនុប្រធានគណបក្សសង្គ្រោះជាតិនិងសកម្មជនវ័យក្មេងគាំទ្រគណបក្សប្រឆាំងម្នាក់ដែលល្បីឈ្មោះយ៉ាងខ្លាំងអំឡុងការបោះឆ្នោតជាតិកាលពីឆ្នាំមុនបានផ្ទុះឡើងម្តងទៀតដោយមានការអះអាងថា សកម្មជនជាសិស្សរូបនេះត្រូវបានគេប្រើប្រាស់នៅក្នុងការខំប្រឹងប្រែងថ្មីមួយ ដើម្បីបំបែកសំឡេងគណបក្សប្រឆាំង។

កញ្ញា ធី សុវណ្ណថា ដែលបច្ចុប្បន្នមានអាយុ ១៩ឆ្នាំបានល្បីឈ្មោះយ៉ាងខ្លាំងអំឡុងការបោះឆ្នោតជាតិកាលពីខែកក្កដា ឆ្នាំ២០១៣ ដោយសារសកម្មភាពរបស់នាងនៅលើទំព័រហ្វេសប៊ុក "I love Cambodia Hot News" ដែលត្រូវបានបង្កើតឡើង **តទៅទំព័រទី ២៣**

# SNRP: activist be used in a new effort to separate the voice of the opposition

**WALLETS MM MIN EVANS** | **OCTOBER 20, 2014**

The quarrel between the eldest daughter of Kem Sokha, deputy director of the National Salvation Party and support young opposition activist who was renowned During national elections last year has erupted again, with the assurance that this student activist be used in a new effort to separate the voice of the opposition.

September Sovann said that currently 19 years old, very famous during the national elections in July 2013 due to activity Her page on Facebook "I love Cambodia Hot News," which was created to help rescue party that they do not allows creation of television during the election campaign.

Popular on her social media has grown very quickly, making her become a leader Among the leaders of the National Salvation Party, but in February the National Salvation Party issued a statement by September expelled from Party. Activists of the National Salvation Party, alleged at the time that Ms. Sovann that are working with the CPP to break voice opposition.

The allegations that have been made to appear again on Friday, September Kem Mono, daughter of Kem Sokha and vice president of public affairs of the rescue party, who wrote on his Facebook page claiming he Ley political analyst and September Sovann There are plans to create a new party.

September Mono wrote that "a new party will be set up, but now they are forming a coalition to monitor reform **Continued to Page 23**

# ខ្សាច់ទន្លេកម្ពុជាត្រូវបានរកឃើញម្តងទៀត នៅក្នុងប្រទេសឥណ្ឌា

**ដោយ គ្រិស ម៉ូល្លឺរ AND អ៊ូច សូនី** | **OCTOBER 17, 2014**

ខ្សាច់ទន្លេកម្ពុជាជិត៨0.000តោន កំពុងស្ថិតនៅកំពង់ផែមួយក្នុងប្រទេសឥណ្ឌាជិត២ខែមកហើយ។ វាជាខ្សាច់ក្នុងចំនួនច្រើនលើកទី២ដែលត្រូវបានរកឃើញនៅទីនោះក្នុងរយៈពេល២ឆ្នាំនេះ ថ្វីបើលោកនាយករដ្ឋមន្ត្រី ហ៊ុន សែន បានចេញបម្រាមហាមមិនឱ្យនាំខ្សាច់ទន្លេចេញកាលពីឆ្នាំ២00៩ក៏ដោយ។

កាសែត The Timeof India បានចុះផ្សាយកាលពីថ្ងៃអង្គារថា ខ្សាច់ទាំងនេះត្រូវបានដឹកចូលកំពង់ផែ Cochin ដែលស្ថិតនៅភាគខាងត្បូងប្រទេសឥណ្ឌាកាលពី២ខែកន្លងទៅនេះ។ ក្រុមហ៊ុន Titanics India Ltd។ ដែលមានមូលដ្ឋាននៅក្នុងក្រុង Chennai និងដែលជាអ្នកនាំចូលខ្សាច់ទាំងនេះ បានឱ្យដឹងថា ខ្សាច់ទាំងនេះបានឆ្លងកាត់គយដោយគ្មានបញ្ហាណាមួយឡើយ ប៉ុន្តែថា ក្រុមហ៊ុនកំពុងមានបញ្ហាក្នុងការស្វែងរកអ្នកទិញ។

លោក Senthilkumar នាយនាវិកដែលធ្វើការឱ្យក្រុមហ៊ុន Titanics India Ltd។ បានប្រាប់កាសែត The Time of India ដោយសំដៅទៅលើក្រុងមួយទៀតដែលនៅក្បែរកំពង់ផែនោះថា "យើងមិនច្បាស់ទេថា តើហេតុអ្វីបានជាគ្មានអ្នកទិញ ខណៈកំពុងមានតម្រូវការខ្លាំងក្នុងរដ្ឋ Kerala។ វាប្រហែលជាមកពីក្រុមម៉ាហ្វីយ៉ាដែលរកស៊ីខ្សាច់ដែរនោះ កំពុងបង្កការលំបាកដល់ពាណិជ្ជកម្មខ្សាច់នេះ"។

មន្ត្រីនៅកំពង់ផែ Cochin ដែលស្នើសុំមិនបញ្ចេញឈ្មោះ ព្រោះលោកមិនត្រូវបានអនុញ្ញាតឱ្យនិយាយជាមួយប្រព័ន្ធផ្សព្វផ្សាយបានឱ្យដឹងកាលពីម្សិលមិញថា កំពង់ផែនេះទទួលនាវាចំនួនពីរគ្រឿងដែលដឹកខ្សាច់កម្ពុជា។ នាវាទី១ដែលដឹកខ្សាច់ប្រមាណ៣៨.៧៥0តោន បានមកដល់នៅចុងខែសីហា ហើយនាវាទី២ដែលដឹកខ្សាច់ប្រមាណ៣៩.000តោន បានមកដល់ប្រហែលជា១ខែបន្ទាប់។ ខ្សាច់ទន្លេកម្ពុជាទាំងនេះត្រូវបាននាំចូលដោយក្រុមហ៊ុន Titanics India កាលពី២ខែកន្លងទៅនេះ។ លោកបានបន្ថែមថា

**តទៅទំព័រទី ២១**

# River sand is found again in India

**GERMAN ENTREPRENEURS AND OUN SONY** | **OCTOBER 17, 2014**

Sand River near 80 .000 tons are at a port in India for nearly 2 months. It was a lot of sand 2nd was discovered there in the past 2 years, despite Prime Hun Sen banned river sand export ban in 2009.

The Timeof India newspaper published on Tuesday that these sands are transported into the port of Cochin in southern India In the past 2 months. Titanics India Ltd. Based in Chennai and who import these sand sand said these cross Customs without any problems, but that the company is having trouble finding buyers.

Senthilkumar officers who work for the company Titanics India Ltd. Told The Time of India, referring to a town near the port, "We are not sure why No buyers, while demand is growing strongly in the state of Kerala. It probably comes from the sand mafia, is making it difficult to trade the sand. "

Officials at the port of Cochin, who asked not to be named because he is not authorized to speak to the media, said yesterday the port received two ships carrying sand. 1st ship carrying approximately 38,750 tons of sand arrived at the end of August and the 2nd ship carrying approximately 39,000 tons of sand about 1 month. These river sand was imported by the company Titanics India in the past 2 months. He added that since then, some sand is shipped and stored in a warehouse but sand, about 50,000 tons are in port.

Port officials had said, "They told us that they could not find buyers. I do not know about the Mafia business sand. I think it is a rumor. "

The official also said that the sand that both ship was listed as a "river sand for export "originating from Cambodia and sand used in construction, but not named exporters.

Hun Sen has banned the export of sand pumped from the river in 2009 in order to protect biodiversity in the water.

Dry inches Secretary of the Ministry of Mines and Energy has confirmed that the sand from the river to export is still illegal, but he Some companies are allowed to export sand pumped from the creek if the licensee.

In November 2013, the Indian media has published about 32 river sand .000 tons, worth about $ 1.5 million customs were arrested at the port of Cochin for more than 6 months.

According to port officials said now these sand already been through customs but firm Raja Steel Private Importers also struggling to find buyers.



# ប្រជាពលរដ្ឋកោះរ៉ុង បោះបង់នេសាទ មកធ្វើអាជីវកម្មលើវិស័យទេសចរណ៍

ប្រជានេសាទដែនសមុទ្រនៅលើដែនកោះរ៉ុងប្រមាណជាង៥០០គ្រួសារ ដែលរស់នៅអចិន្ត្រៃយ៍បានបោះបង់ការធ្វើនេសាទដោយផ្សងព្រេងងាកមកធ្វើអាជីវកម្មលើវិស័យទេសចរណ៍វិញ ប៉ុន្តែការប្រកបរបរវិស័យទេសចរណ៍របស់ពួកគាត់នៅមិនទាន់ប្រាកដថា មានអនាគតល្អនៅឡើយទេ ដោយសារតែទីតាំងមុខរបរពួកគាត់ស្ថិតក្នុងជម្លោះដីធ្លីជាមួយក្រុមហ៊ុនអភិវឌ្ឍនៅលើដែនកោះនោះ។ ម្ចាស់បឹងកាឡូមួយ នៅលើដែនកោះរ៉ុងនោះ បានថ្លែងពីក្តីព្រួយបារម្ភថា ដែនកោះរ៉ុងនោះ មានក្រុមហ៊ុនវិនិយោគមួយតែងកើតជម្លោះដណ្តើមដីធ្លីជាមួយពលរដ្ឋដែលជាម្ចាស់ដីតាំងពីយូរយារមកហើយ ។ ជម្លោះនោះអាជ្ញាធរខេត្តពុំបានដោះស្រាយនៅឡើយទេ។ ការប្តូរមុខរបររបស់ប្រជានេសាទនៅលើដែនកោះរ៉ុង នាពេលបច្ចុប្បន្នត្រូវបានចៅសង្កាត់កោះរ៉ុងលោក អ៊ូង និត ថ្លែងប្រាប់រស្មីកម្ពុជាថា សព្វថ្ងៃនេះមានបងប្អូនប្រជានេសាទបានប្តូរមុខរបរងាកមកធ្វើអាជីវកម្មវិស័យទេសចរណ៍វិញប្រមាណ៨៥ភាគរយទៅហើយ។ ចំពោះការធ្វើនេសាទនៅមានប្រហែល១០ភាគរយ និងមុខរបរមិនពិតប្រាកដមានប្រហែល៥ភាគរយតែប៉ុណ្ណោះ។ លោកចៅសង្កាត់កោះរ៉ុងរូបនោះ បានថ្លែងកោតសរសើរដល់ប្រជាពលរដ្ឋនៅលើដែនកោះរ៉ុងថា ពលរដ្ឋរស់នៅលើដែនកោះរ៉ុង មិនថា ក្មេងឬចាស់ទេ ពួកគាត់ចេះភាសាអង់គ្លេសស្ទើរទាំងអស់គ្នា ដោយអ្នកខ្លះគ្មានបឹងកាឡូឬផ្ទះសំណាក់ ឬហាងលក់ដូរនឹងគេ ក៏មានទូកនេសាទសម្រាប់ដឹកភ្ញៀវទៅកម្សាន្តជុំវិញកោះមើលផ្កាថ្មដែលជាសម្បត្តិធម្មជាតិបាតសមុទ្ររបស់ខ្មែរដែរ ។ ឥឡូវនេះប្រជាពលរដ្ឋនៅលើដែនកោះរ៉ុងភាគច្រើនមានជីវភាពធូរធារណាស់ បើប្រៀបធៀបទៅនឹងកាលពីអាណត្តិមុនខុសគ្នាឆ្ងាយណាស់។ ទោះជាយ៉ាងនេះក្តីពលរដ្ឋនៅដែនកោះរ៉ុង ក្រុងព្រះសីហនុ សូមអំពាវនាវដល់គណបក្សនយោបាយធំៗដែលឈ្នះឆ្នោតមេត្តាបង្រួបបង្រួមជាតិឱ្យបានឆាប់ៗទៅ ដើម្បីជៀសវាងការបង្កភ័យខ្លាចដល់ភ្ញៀវទេសចរអន្តរជាតិ ព្រោះភ្ញៀវទាំងនោះជាឆ្នាំងបាយតែមួយគត់សម្រាប់ពួកគាត់ក្នុងវិស័យទេសចរណ៍នៅលើដែនកោះរ៉ុង ក្រុងព្រះសីហនុ ។ សូមបញ្ជាក់ដែរថា នៅលើដែនកោះរ៉ុង សព្វថ្ងៃមានប្រជាពលរដ្ឋរស់នៅអចិន្ត្រៃយ៍ចំនួន៥០៦គ្រួសារ និងភ្ញៀវជាតិ-អន្តរជាតិមួយចំនួនផងដែរ៕











# ជាតិ សាសនា ព្រះមហាក្សត្រ (ត)




ពាក្យទាំងបីនេះគឺជាបាវចនារបស់ព្រះរាជាណាចក្រកម្ពុជា ដែលចែងក្នុងរដ្ឋធម្មនុញ្ញមាត្រាទី ៤ ហើយអាជ្ញាធរតែងតែចងប៉ាដាពេញទីក្រុងភ្នំពេញ នៅពេលបុណ្យជាតិម្តងៗ ដូចមានរូបខាងក្រោមនេះ ។

ហើយនិងមានពាក្យស្លោកផ្សេងៗទៀត ដូចជា "ជយោ! ការបង្រួបបង្រួមជាតិ ជយោ! លទ្ធិប្រជាធិបតេយ្យ ជយោ! សេរីពហុបក្ស ជយោ! អភិឱ្ឍន៏ ការពារផ្តួរផ្តាច់រដ្ឋធម្មនុញ្ញ ។ល។" ទង្វើនេះ ដូចជារដ្ឋាភិបាលគោរពរដ្ឋធម្មនុញ្ញ ឥតខ្ចោះតែការពិតយ៉ាងដូចម្តេចទៅវិញ ?

កាលពីព្រះរាជពិធីខួបឆ្នាំទី១០ នៃការគ្រងព្រះបរមរាជសម្បត្តិ ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថនរោត្តម សីហមុនី ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជាកាលពីថ្ងៃទី ២៩ តុលា ឆ្នាំ ២០១៤ ហើយថ្ងៃនេះអាជ្ញាធរក៏ចាត់ទុកជាបុណ្យជាតិ ព្រមទាំងអនុញ្ញាតឱ្យមន្ត្រីរដ្ឋការឈប់សំរាកមួយថ្ងៃ ។តែពិធីការអត់បាននិមន្តព្រះសង្ឃមកចូលរួមទេ ព្រះសង្ឃ គឺតំណាងឱ្យស្ថាប័នសាសនា ដែលមានចែងនៅក្នុងបាវចនារបស់ព្រះរាជាណាចក្រកម្ពុជា ។ ដូចជាពិធីការបំភ្លេចស្ថាប័ននេះចោលដោយចេតនា ។ ព្រមទាំងអាជ្ញាធរបញ្ជាឱ្យកងកម្លាំងដេញវាយព្រះសង្ឃជាញឹកញាប់ នៅពេលព្រះសង្ឃហែរបាតុកម្មទាមទារសិទ្ធិ ជាពិសេសហែរបាតុកម្មគាំទ្រព្រះសង្ឃខ្មែរក្រោម ដែលអាជ្ញាធរយួនរំលោភសិទ្ធិលើសិទ្ធិប្រជាពលរដ្ឋភាគតិច ។

ការបំភ្លេចនេះមានម្តងទៅហើយកាលពីពិធីបុណ្យគោរពព្រះវិញ្ញាណខ័ន្ធព្រះបរមរតនកោដ្ឋសម្តេចនរោត្តមសីហនុគំរប់ខួបពីរឆ្នាំកាលពីថ្ងៃទី១៥ ខែតុលាឆ្នាំ ២០១៤ ដោយមិនអញ្ជើញតំណាងរាស្ត្រទាំង៥៥ រូបរបស់គណបក្សសង្គ្រោះជាតិដែលផ្ទុយនឹងពាក្យស្លោកដែលថា "ជយោ! ការបង្រួបបង្រួមជាតិ"នោះ។ ហើយថ្ងៃនេះក៏អាជ្ញាធរចាត់ទុកជាបុណ្យជាតិដែរ ព្រមទាំងអនុញ្ញាតឱ្យមន្ត្រីរដ្ឋការឈប់សំរាកមួយថ្ងៃ ។

យើងសង្កេតឃើញ កាលពីព្រះរាជពិធីខួបឆ្នាំទី១០នេះ មានអវត្តមានតំណាងរាស្ត្រ និងព្រឹទ្ធសភាជាច្រើនរូប នេះបង្ហាញពីភាពមិនប្រក្រតីក្នុងពិធីបុណ្យជាតិដែលតំណាងប្រជាជាតិមិនបានមកចូលរួម ។

ព្រមទាំងសុន្ទរកថាតំណាងអង្គមីទិញ ឯកឧត្តម ប៉ា សុជាតិវង្ស អភិបាលនៃគណៈអភិបាលរាជធានីភ្នំពេញមិនបានរំលឹកពីស្ថាប័នសាសនាដែលចែងនៅក្នុងបាវចនារបស់ព្រះរាជាណាចក្រកម្ពុជានោះទេ បែរជារំលឹកជាច្រើនដងពី "សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុនរ៉ានី សម្តេចអគ្គមហាចក្រី ហេងសំរិន សម្តេចអគ្គមហាធម្មពោធិសាល ជា ស៊ីម" ។ ហេតុនេះខ្ញុំសូមជូនយោបល់ឱ្យដូរបាវចនាទាំងបីពាក្យ "ជាតិ សាសនា ព្រះមហាក្សត្រ" ទៅជា "សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន សម្តេចកិត្តិព្រឹទ្ធបណ្ឌិត ប៊ុន រ៉ានី)

១- សម្តេចអគ្គមហាពញាចក្រី ហេងសំរិន សម្តេចអគ្គមហាធម្មពោធិសាលជាស៊ីម ព្រះ-មហាក្សត្រ" ទៅវិញ ឱ្យសក្តិសម និងស្របទៅនឹងស្ថានភាពនយោបាយនៅប្រទេសខ្មែរសព្វថ្ងៃនេះ ។

**លិម គិមយ៉ា**

តំណាងរាស្ត្រមណ្ឌលកំពង់ធំ

សមាជិកគណៈកម្មការសេដ្ឋកិច្ចហិរញ្ញវត្ថុធនាគារនិងសវនកម្មនៃរដ្ឋសភា

(១)បើតាមអ្នកកំប្លែងឈ្មោះគ្រឿនបានឱ្យអត្ថន័យពាក្យកិត្តិព្រឹទ្ធបណ្ឌិត ថាជា "អ្នកបណ្ឌិតចេះចិញ្ចឹមកូនទា" ៕

---

# ទេសចរទៅលេងប្រទេសវៀតណាម
## គួរប្រយ័ត្នប្រយែងរឿងងូតទឹកព្រែក,ទន្លេ,ជ្រោះ

**គីម ភឿន**



ទេសចរជនជាតិអង្គលេសម្នាក់ក្រោយពេលត្រឡប់មកពីដើរលេងកំសាន្តនៅប្រទេសវៀតណាម...បាននាំមកជាមួយនូវសត្វល្អិតមួយក្នុងច្រមុះ! នោះគឺនៅថ្ងៃព្រហស្បត្តិ៍ទី១៦,១០,២០១៤វេលាម៉ោង១២:១២នាទីល្ងាចទេសចរជនជាតិអង្គលេសម្នាក់បាននាំមកជាមួយខ្លួននូវអំណោយអនុស្សាវរីយ៍មួយដែលខ្លួនមិនចង់បានទាល់តែសោះពេលមកពីដំណើរទេសចរនៅវៀតណាមនោះជាសត្វល្អិតមួយធំប្រហែលប៉ុនចង្អុលដៃប្រវែង៧សង់ទីម៉ែតនៅក្នុងរន្ធច្រមុះ។ មិនតិចទេ ដែលមានករណីល្អិតចូលទៅសមំក្នុងរន្ធច្រមុះ ហើយថ្មីៗនេះជាករណីរបស់ទេសចរនារីម្នាក់មកពីប្រទេសអង្គលេស ។ នារីទេសចរនេះមាននាមថា Daniela Liverina បានធ្វើទេសចរកំសាន្តពាសពេញដំបន់អាស៊ីបូពារ ហើយចាប់ពីពេលនោះមកនាងចេះតែចេញឈាមតាមច្រមុះជានិច្ចអន្ទង់រុក) ។ ពីបីថ្ងៃក្រោយមកនាងបានត្រឡប់ទៅផ្ទះនាងឯ Edinburgh ហើយបានពិនិត្យឃើញមានសត្វល្អិតមួយនៅក្នុងរន្ធច្រមុះខាងស្តាំរបស់នាង ប៉ុន្តែនាងចេះតែស្មានថានោះជាដុំឈាមកកក្នុងគ្រោះថ្នាក់ចរាចរមួយបានកន្លងផុតមកហើយ។ នាងបានឱ្យដឹងថា "ខ្ញុំចេះតែខំញឹសសំបោរឱ្យដុំឈាមកកនោះចេញមកក្រៅតែមិនព្រមចេញសោះ,ពេលខ្ញុំងូតទឹកល្អិតនោះលានខ្លួនចេញមកដល់បរបូរមាត់ខ្ញុំ,ប៉ាស់វា៧លីបបាត់ចូលទៅក្នុងរន្ធច្រមុះវិញទៅ,ពេលដែលដឹងថា មានរឿងចំឡែកយ៉ាងនេះខ្ញុំក៏រត់ទៅរកកញ្ចក់មកឆ្លោះទើបដឹងរឿងពិតថាមានសត្វល្អិតនៅក្នុងច្រមុះខ្ញុំ។ ដឹងយ៉ាងណឹងហើយទើបនាងហៅរកមិត្តភ័ក្តិ,គេក៏ដឹកនាំនាងទៅមន្ទីរពេទ្យ។ លោកវេជ្ជបណ្ឌិតបានខំប្រឹងប្រែងអស់ពេលកន្លះម៉ោងជាមួយនឹងពន្លឺហ្វាបញ្ចាំងព្រមទាំងដង្កៀបដើម្បីខំប្រឹងទាញយកវាចេញមកឱ្យបាន។ "វាឈឺចាប់ខ្លាំងណាស់ " នាងបានថ្លែងប្រាប់គេគ្រប់គ្នានៅទីនោះ។ លោក Mark sidal អ្នកគ្រប់គ្រងសារៈមន្ទីរប្រវត្តិសាស្ត្រធម្មជាតិនៅក្រុងញីវយ៉កហើយជាអ្នកឯកទេសពីសត្វល្អិតផងនោះបានឱ្យដឹងបន្ថែមថា "នាងលីវីរីណា អាចត្រូវបានសត្វល្អិតនេះរុកចូលក្នុងច្រមុះពេលនាងកំពុងនៅឯប្រទេសវៀតណាមដែលបានហែលទឹកលេងឬល្អិតអាចចូលតាមមាត់ពេលនាងផឹកទឹក"។ សរសេរតាមដំណឹងនៃសារព័ត៌មានបរទេសតាមប្រព័ន្ធយូធូប ៕






**សេចក្តីផ្តើម :**

នេះជារឿងប្រលោមលោកខ្លីដ៏ពិតមួយដែលបានកើតឡើងនៅក្នុងភូមិមួយនៅលើដែនដីសុវណ្ណ រដ្ឋា ក្នុងអំឡុងពេលប្រមាណជា៦០០ឆ្នាំមុន ។

ធ្វើឱ្យមនុស្សសម័យនេះដឹងដោយសារការនិទានប្រាប់គ្នាពីជំនាន់មួយទៅជំនាន់មួយ រហូតបានបណ្តាលឱ្យអ្នកមានសតិស្មារតីជាប់ចិត្ត ក៏បានលើករឿងនេះមកចងក្រងរៀបរៀងជារឿងប្រលោមលោកខ្លីដ៏ពិតមួយរឿង ។ ដោយចង់ឱ្យជនានុជនបានអានហើយយកមកសិក្សាពិចារណារៃកញែកអំពីអត្ថន័យខ្លឹមសារដែលមានបង្កប់ទុកនៅក្នុងសាច់រឿងនេះឱ្យបានឃើញច្បាស់ ហើយយកមកតម្កល់ទុក នៅក្នុងចិត្តប្រចាំជីវិតរបស់ខ្លួន និងគ្រួសារឱ្យបានជួបប្រទះតែនឹងសេចក្តីស្ងប់សុខនិងសុភមង្គលផង ។

**ដំណើររឿងមានដូចតទៅ :**

ភូមិណុភធំជាភូមិមួយមាន ទេសចរណ៍ដ៏ល្អប្រណិតគយួរឱ្យចង់រស់នៅណាស់ ។

នៅក្នុងភូមិនេះ មានគេហដ្ឋានជាច្រើន សង់ជាជួរមានរបៀបរៀបរយ ក្រោមម្លប់នៃរុក្ខជាតិតូចធំដ៏ត្រសំត្រសាយ មានខ្យល់អាកាសត្រជាក់បក់មកយ៉ាងត្រសៀក១អង្រន់ស្លឹកឈើឮស្រាវ១ហាក់បីដូចជាសម្លេងតន្រ្តីប្រគំរងំលាយទៅដោយសម្លេងបន្ទរយ៉ាងខ្សៀវខ្សានៃបក្សាបក្សី ។ យូរ១ម្តងគេឮស្នូរសម្លេងឆ្កែព្រូស និងសម្លេងមាន់រងាវបញ្ជាក់ឱ្យដឹងថា នៅក្នុងភូមិនេះ មានបណ្តាជនរស់នៅយ៉ាងសុខសាន្ត មានការរាប់អានគ្នាយ៉ាងល្អប្រពៃ ។

នៅក្នុងគេហដ្ឋាននិមួយ១សុទ្ធសឹងមានសមាជិកគ្រួសាររស់នៅដែលមានឪពុកម្តាយ កូនចៅ នៅជួបជុំគ្នាទៅតាមទំហំនៃគ្រួសារនិមួយ១ ។ គ្រួសារខ្លះមានមនុស្សតិច គ្រួសារខ្លះមធ្យម និងគ្រួសារខ្លះមានមនុស្សច្រើនលើសលប់ ។

ការដែលមានទំហំគ្រួសារ មិនដូចគ្នានេះហើយ ធ្វើឱ្យគ្រួសារនិមួយ១មានការគ្រប់គ្រងនិងដឹកនាំមិនដូចគ្នាដែរ ។ គ្រួសារមានមនុស្សតិចក៏មានបញ្ហាតិច រីឯគ្រួសារមានមនុស្សច្រើន ក៏មានបញ្ហាច្រើនដែរ ។

ដូច្នេះទើបធ្វើឱ្យមេគ្រួសារនិមួយ១ ត្រូវតែរិះរកវិធីគ្រប់បែបយ៉ាង ដើម្បីដោះស្រាយ និងសម្រួលក្នុងគ្រួសាររបស់ខ្លួនធ្វើយ៉ាងណាឱ្យគ្រួសារបានរស់នៅដោយសុខសាន្ត និងចំរុងចំរើន ។ បើពុំនោះសោតទេ មុខនឹងជួបការលំបាកបន្តិចម្តង១នៅពេលបច្ចុប្បន្ន និងទៅអនាគត ។

សភាវៈទាំងនេះហើយ ដែលបណ្តាលឱ្យគេហដ្ឋានពីរដែលមានរបងជាប់គ្នា ហើយគ្រួសារមួយមានគ្នាតិច គឺមានឪពុកម្តាយ កូនប្រុសមួយ និងកូនស្រីមួយ ។ អ្នកទាំង៤នាក់នេះបានរស់នៅយ៉ាងសុខសាន្ត និងចំរុងចំរើនជាទីបំផុត ដោយមានគេហដ្ឋានក៏ធំល្មមសម្រាប់ជ្រកកោន មានចំការស្រែប្រកបការងារ ជាដំណាំយកមកផ្គត់ផ្គង់គ្រួសារបានយ៉ាងល្អ ដោយមានចំការស្រែសម្រាប់បង្កបង្កើនផលជាច្រើនហិកតា ។

រីឯគ្រួសារមួយទៀត មានគ្នាច្រើនគឺ ឪពុកម្តាយកូនប្រុសចំនួនបីនាក់ និងកូនស្រីចំនួន៣នាក់ ។ អ្នកទាំង៨នាក់នេះ តែងតែជួបប្រទះនឹងការលំបាកលំបិនគ្រប់បែបយ៉ាង គឺគេហដ្ឋានក៏មិនធំប៉ុន្មាន និងមានចំការស្រែសម្រាប់បង្កបង្កើនផលក៏តិចដែរ ដែលពុំអាចមានលទ្ធភាពគ្រប់គ្រាន់នៅក្នុងការចិញ្ចឹមជីវិតគ្រួសារ ។ ម្លោះហើយ ទើបមេគ្រួសារនេះខិតខំរិះរកមធ្យោបាយផ្សេង១ ដើម្បីកែខៃបញ្ហាដ៏លំបាកនេះ ។ ទើបសម័យថ្ងៃមួយនៅពេលល្ងាច ក្រោយបានបរិភោគអាហារពេលល្ងាចរួចហើយ ទាំងអស់គ្នាក៏រកកន្លែងសំរាកពេលយប់រៀង១ខ្លួន ។

កូនប្រុសស្រីក៏បានទៅសម្រាកយ៉ាងស្ងប់ស្ងាត់ពុំមានអ្វីកង្វល់អ្វីនៅក្នុងចិត្តទេ ពីព្រោះពួកគេ គឺពឹងផ្អែកទាំងស្រុងទៅលើឪពុកម្តាយជាអ្នកបង្កើតខ្លួនមក ។

ចំណែកប្តី និងប្រពន្ធជាឪពុកម្តាយពេលចូលដំណេកក៏ពុំអាចលក់ទៅដោយងាយដែរ ដោយសារមានកង្វល់ច្រើនចំពោះបញ្ហាក្នុងគ្រួសាររបស់ខ្លួន ។ បុរសជាប្តីក៏ផ្តើមនិយាយទៅកាន់ប្រពន្ធថា : សព្វថ្ងៃយើងកំពុងតែជួបប្រទះនូវបញ្ហាជាច្រើនដូចជាផ្ទះតូចចង្អៀត ដោយកូនកាន់តែធំឡើង ។ ការចិញ្ចឹមកូនក៏ពុំមានម្ហូបអាហារគ្រប់គ្រាន់ គួរឱ្យព្រួយបារម្ភណាស់ ។ ចំការស្រែក៏មានមិនធន់ល្មមតាមសេចក្តីត្រូវការ ដែលត្រូវបង្កបង្កើនផលឱ្យបានច្រើនយកទៅលក់បានកំរៃមកផ្គត់ផ្គង់គ្រួសារឱ្យបានគ្រប់គ្រាន់ដែរ ។ តើយើងត្រូវធ្វើដូចម្តេច ?

ប្រពន្ធក៏បានឆ្លើយទៅប្តីថា នេះជាកាព្វកិច្ចរបស់យើងជាឪពុកម្តាយហើយ ដូច្នេះយើងត្រូវតែខិតខំរិះរកវិធីដោះស្រាយ តើត្រូវដោះស្រាយដូច្នេះ? ។ ពេលស្ងៀមស្ងាត់សំងំជិតមួយសន្ទុះ ទើបបុរសជាប្តីស្រដីឆ្លើយទៅកាន់ប្រពន្ធថា គ្រួសារមួយទៀត ដែលគេនៅជាប់របងផ្ទះយើងនេះ គេមានភ័ព្វសំណាងណាស់ ដោយគេមានកូនតែពីរនាក់ប្រុសមួយស្រីមួយ គេមានគេហដ្ឋានធំទូលាយ គេមានចំការស្រែច្រើនថែមទៀត ។ ដូច្នេះយើងត្រូវរករិះវិធីយ៉ាងណា ដើម្បីឱ្យកូនស្រីដ៏ស្រស់ឆើតឆាយ ឱ្យបានក្លាយទៅជាប្រពន្ធរបស់កូនប្រុសតែមួយរបស់គេទៅ ពីព្រោះកូនប្រុសគេនេះក៏មានរូបរាងសង្ហា ស្លូតបូត ទៀងត្រង់ចេះដឹង សុភាពខែងរែងថែមទៀត គួរឱ្យស្រលាញ់ណាស់ ។ ដើម្បីឱ្យការនេះបានសម្រេចយើងត្រូវទៅនិយាយពន្យល់កូនស្រីយើងឱ្យវារកពេលទៅជួបកូនប្រុសគេនោះ ហើយឱ្យវាសម្តែងការស្រលាញ់រាប់អានយ៉ាងជិតស្និតជាមួយគេរហូតដល់ធ្វើឱ្យកូនប្រុសគេនោះ ឈ្លក់នឹងសម្រស់ដ៏ប្រិមប្រិយ ជាប់ចិត្តស្រលាញ់ប្រតិព័ទ្ធយ៉ាងស៊ុប ហើយក៏តាំងសុំឱ្យឪពុកម្តាយគេចូលមកស្តីដណ្តឹងកូនស្រីយើង នេះជាតំណាក់កាលត្រូវដោះស្រាយលើកទី១ ។ យើងនឹងមានផែនការត្រូវធ្វើជាបន្តបន្ទាប់ទៀត លុះត្រាតែបានសម្រេចជោគជ័យជាស្ថាពរ ។

កាលប្រពន្ធបានឮប្តីនិយាយរៀបរាប់រួចហើយ ប្រពន្ធក៏គិតថា នេះជាវិធីមួយដ៏ល្អប្រសើរដែរ ទើបឆ្លើយតបថា គំនិតដ៏ល្អរបស់បងនេះខ្ញុំយល់ស្របហើយ យើងត្រូវតែចាត់ការផ្តើមធ្វើរឿងនេះ ចាប់ពីថ្ងៃស្អែកនេះតទៅ ។

ទាំងពីរនាក់ក៏សម្រាកយ៉ាងសុខសាន្តក្នុងរាត្រីនោះ លុះព្រឹកឡើងប្តីប្រពន្ធទាំងពីរ ក៏បានហៅកូនស្រីដ៏ស្រស់ប្រិមប្រិយមួយមកនិយាយពន្យល់ណែនាំ ដូចគំនិតរបស់ខ្លួន ដែលបានពិគ្រោះជាមួយគ្នាកាលពីយប់ ។

ដោយកូនស្រីបានយល់អំពីកង្វល់របស់ឪពុកម្តាយ ចំពោះកូន កូនប្រុសស្រីទាំងអស់ ទើបកូនស្រីក៏បានយល់ព្រមស្របតាមដំបូន្មានឪពុកម្តាយទាំងស្រុង ។

មិនយូរប៉ុន្មាន គេឃើញនាងស្រីស្រស់ដ៏ស្អាតប្រិមប្រិយឈ្មោះនាង អែម បានព្យាយាមរកឱកាសល្អ ដើម្បីស្កាត់ទៅជួបនឹងមាណពដ៏សង្ហាកូនប្រុសរបស់គ្រួសារដែលនៅជិតគ្នាឈ្មោះ ខេមរា ។ ជារៀងរាល់ថ្ងៃគេតែងតែឃើញអ្នកទាំងពីរជួបគ្នានិយាយសារសងគ្នាដោយទឹកមុខរីករាយបង្ហាញឱ្យដឹងថា អ្នកទាំងពីរមានការពេញចិត្តគ្នាទៅវិញទៅមក ។

ពីមួយថ្ងៃទៅមួយថ្ងៃ អ្នកទាំងពីរបានសារសងគ្នាយ៉ាងទៀតទាត់ ហើយការរាប់អានគ្នា ក៏កាន់តែជិតស្និទ្ធឡើង១ ប្រហែលជាមិនយូរទេ អ្នកទាំងពីរមុខជារកវិធីយ៉ាងណា ដើម្បីឱ្យឪពុកម្តាយរៀងខ្លួនយល់ព្រមបំពេញមុខនាទីមួយថា ត្រូវតែផ្សំផ្គុំអ្នកទាំងពីរឱ្យបានក្លាយទៅជាគូស្វាមីភរិយារស់នៅជាមួយគ្នា ហើយបានបង្កើតជាគ្រួសារថ្មីមួយទៀតសម្រាប់បន្តវង្សត្រកូលតទៅមុខទៀត ។

កន្លងមកមិនបានប៉ុន្មានខែផង គេឃើញពិធីអាពាហ៍ពិពាហ៍មង្គលការមួយ បានប្រារព្ធធ្វើឡើងយ៉ាងឧឡារិកគគ្រឹកគគ្រេងនៅគេហដ្ឋានខាងស្រី ។ បន្ទាប់មកគូស្វាមីភរិយាថ្មោងថ្មីនេះ ក៏បានសូមលាលោកឪពុកអ្នកម្តាយខាងស្រីទៅរស់នៅជាមួយឪពុកម្តាយខាងប្រុស ។ ដូច្នេះឪពុកម្តាយទាំងពីរគ្រួសារបានក្លាយទៅជាដន្លងនឹងគ្នាមានការរាប់អានគ្នា ហាក់បីដូចជាគ្រួសារតែមួយចាប់តាំងពីពេលនេះទៅ ។

ឪពុកម្តាយនាង អែម កាលបើបានឃើញថាកូនស្រីបានទៅយកប្តីឈ្មោះ ខេមរា ហើយ គាត់មានសេចក្តីសប្បាយរីករាយណាស់ ពីព្រោះវិធីទី១ ដែលគាត់ចង់ធ្វើនោះ បានសម្រេចហើយ ។ ហើយបន្ទុកគ្រួសាររបស់គាត់ត្រូវបានធូរស្រាលមួយកម្រិតដែរ ។ ប៉ុន្តែគាត់ត្រូវរកវិធី ដើម្បីធ្វើបនតទៅទៀត ។ ទើបគាត់រកឱកាសពិភាក្សាជាមួយប្រពន្ធគាត់ទៀត ។

យប់មួយដ៏ស្ងាត់ជ្រងំនៅក្នុងភូមិលាភធំបុរសជាប្តីបានចាប់ផ្តើមនិយាយទៅកាន់ប្រពន្ធថា កូនស្រី អែម យើងបានមានប្តីហើយ ហើយគេទៅនៅជាមួយប្តី ហើយយើងទាំងពីរក៏ក្លាយទៅជាដន្លងនឹងគ្នាដែរ ។ ដូច្នេះទំនាក់ទំនងរវាងគ្រួសារយើងទាំងពីរ ក៏ត្រូវបានល្អប្រសើរដែរ ។ នេះជាការល្អហើយ ជាភ័ព្វសំណាងយើងហើយដែលយើងត្រូវតែរិះរកវិធីថ្មី ធ្វើដូចម្តេចដើម្បីឱ្យបន្ទុកគ្រួសារបានកាន់តែធូរស្រាលបន្តិច១ម្តងតទៅមុខខ្ញុំគិតថា ឱ្យកូនប្រុសកូនស្រីទៅជួយធ្វើកិច្ចការចំការស្រែ ខាងដន្លងនោះ ឱ្យបានទៀងទាត់ឱ្យអស់ពីកម្លាំងកាយកម្លាំងចិត្ត ពីព្រោះគេមានចំការស្រែច្រើន ហើយបើមានចំការស្រែណាធ្វើពុំអស់ក៏សូមប្រវាស់យកមកធ្វើខ្លះ ដើម្បីឱ្យគ្រួសារទាំងពីរកាន់តែចំរុងចំរើនឡើង មានការរស់នៅបានធូរធារទាំងអស់គ្នា ។ រីឯគេហដ្ឋានដ៏ដូច្នោះដែរ បើផ្ទះយើងចង្អៀតចង្អល់ក៏យើងសុំទៅស្នាក់នៅផ្ទះ ខាងដន្លងខ្លះទៅទំរាំយើងពង្រីកផ្ទះសម្បែងយើងបាន ។

ការគិតបែបនេះ ធ្វើឱ្យប្រពន្ធមានការសប្បាយរីករាយម្តងទៀត ដោយគិតថា គំនិតនេះមុខជាបានសម្រេចម្តងទៀត ជាមិនខាន ទើបឆ្លើយទៅប្តីថា ខ្ញុំពេញចិត្តណាស់នឹងគំនិតនេះ។

ចាប់តាំងពីពេលនោះមក គេឃើញគ្រួសារទាំងពីរដែលមានគេហដ្ឋាននៅជិតគ្នាស្រាប់ បានចេញចូលទៅមករកគ្នាយ៉ាងរីករាយ ប្រៀបបានគ្រួសារតែមួយ ។ ហើយអ្វី១ដែលឪពុកនាង អែម

**តទៅទំព័រទី ២២**

## តមកទំព័រទី ១៦ បណ្តេញព្រះសង្ឃស្នើឱ្យរដ្ឋាភិបាលពិនិត្យ...

ប្រធានបណ្តាញព្រះសង្ឃឯករាជ្យព្រះតេជគុណ ថង ណារិទ្ធិ មានសង្ឃដីកាថា នេះជាសកម្មភាពអសីលធម៌របស់មន្ត្រីសង្ឃ និងមន្ទីរធម្មការខេត្ត ដោយប្រើអាជ្ញាធរគាបសង្កត់ក្នុងការដោះស្រាយបញ្ហានេះ ហេតុនេះព្រះអង្គស្នើនាយករដ្ឋមន្ត្រីពិចារណាពីការដោះស្រាយបញ្ហានេះ ។ ព្រះតេជគុណមានសង្ឃដីកាថា ឈប់ប្រើអាជ្ញាធរទៅគាបសង្កត់តាមរយៈមន្ត្រីសង្ឃអាជ្ញាធរដែនដីសូមឱ្យសម្តេចបញ្ឈប់ការធ្វើបាបដល់ព្រះសង្ឃតទៅទៀត ។

សមាជិកសកម្មបណ្តាញព្រះសង្ឃឯករាជ្យ ណាំ ចាន់ថេន អះអាងថា សកម្មភាពដកតំណែង និងការបណ្តេញចេញជាការរំលោភសិទ្ធិព្រះសង្ឃធ្ងន់ធ្ងរ ពីព្រោះថា សកម្មភាពកន្លងមកជាសកម្មភាពមនុស្សធម៌ និងមិនមានពាក់ព័ន្ធនយោបាយ ឬនិន្នាការទៅបក្សណានោះទេ ប៉ុន្តែចំពោះរាជរដ្ឋាភិបាលកាន់អំណាចបច្ចុប្បន្នចោទព្រះអង្គជាអ្នកនយោបាយធ្វើការឱ្យបក្សប្រឆាំង ។

អ្នកនាំពាក្យក្រសួងធម្មការ និងសាសនា លោក សេង សុមុន្នី មានប្រសាសន៍ថា ចំពោះបញ្ហានេះក្រសួងបានបញ្ជាឱ្យមន្ទីរធម្មការខេត្តធ្វើរបាយការណ៍ជាបន្ទាន់មកក្រសួង ដើម្បីពិនិត្យមើលតាមផ្លូវច្បាប់ ថាមានការខុសឆ្គងត្រង់ចំណុចណាមួយ ហើយត្រូវចាត់វិធានការផ្សេងៗដោយមាននីតិវិធីដាក់បញ្ហា ឬចុះទៅពិនិត្យជាក់ស្តែង ។

ព្រះតេជគុណ ប៊ុត ប៊ុនតិញ លើកឡើងថា ប្រសិនបើមិនមានការដោះស្រាយពីបញ្ហានេះថា បណ្តាញព្រះសង្ឃឯករាជ្យនឹងធ្វើធម្មយាត្រាពីបាត់ដំបងទៅភ្នំពេញ ដើម្បីផ្សព្វផ្សាយពីបញ្ហាខុសឆ្គងផ្សេងៗរបស់ព្រះសង្ឃធ្វើកូដកម្មក្នុងវត្តភ្នំខ្ពស់ និងដាក់ញត្តិទៅក្រសួងធម្មកា និងសាសនាដោះស្រាយពីបញ្ហានេះ ។

ព្រះចៅអធិការវត្តភ្នំខ្ពស់ ព្រះតេជគុណ ឃឹម សំអឿន ត្រូវបានដកតំណែងចេញនៅថ្ងៃទី១៩ ខែតុលា ដែលជំនួសដោយព្រះចៅអធិការថ្មី ព្រះតេជគុណ ដួង សុខុម ។ ចំណែកភិក្ខុ ពត ជីវ័ន្ត ត្រូវបានបណ្តេញពីវត្តដំណាក់បេងនៅអំឡុងខែឧសភា ហើយព្រះអង្គទាំងពីររងការចោទពីការធ្វើសកម្មភាពក្រោមរូបភាពនយោបាយ ៕

Continued from page 16

## Web monks asked the government...

Nam Chan Thein claimed that the removal action and evicted the monks serious rights violations because that action springs human activities and no relevant political party or trend, but the current government to power accused opposition politicians.

A spokesman for the Ministry of Cults and Religions, Seng Mony said on this matter, the Ministry ordered Cult immediate reporting to the Ministry to check legal point mistakes and have to do something different with a procedural order or visiting practice.

Buntenh Bun buy that if not resolve the issue that network independent monks will make the pilgrimage from Battambang to Phnom Penh to a widespread problem liberalism monks strike in Wat Phnom and regulations to the Department of Natural and resolve the issue.

Wat Phnom monk Venerable Khim Sam Ouen was stripped of his replacement on 19 October by the new monk Venerable Duong welfare. Ven physical being expelled from Wat cup stage during both May and he has been accused of political action under the picture.

## តមកទំព័រទី ១៧ ខ្សាច់ទន្លេកម្ពុជាត្រូវបានរកឃើញម្តង...

ចាប់តាំងពីពេលនោះមកខ្សាច់មួយចំនួនត្រូវបានដឹកជញ្ជូនទៅទុកនៅឃ្លាំងមួយចំនួន ប៉ុន្តែនៅមានខ្សាច់ប្រហែល៥០.០០០តោនទៀតកំពុងនៅកំពង់ផែ ។

មន្ត្រីកំពង់ផែរូបនេះបាននិយាយថា "គេបានប្រាប់យើងថា គេមិនអាចរកអ្នកទិញបានទេ ។ ខ្ញុំមិនដឹងអំពីក្រុមម៉ាហ្វីយ៉ាដែលរកស៊ីខ្សាច់នេះទេ ។ ខ្ញុំគិតថា វាគឺជាពាក្យចចាមអារ៉ាម" ។

មន្ត្រីរូបនេះបានឱ្យដឹងទៀតថា ខ្សាច់ដែលដឹកតាមនាវាទាំងពីរត្រូវបានចុះបញ្ជីជា "ខ្សាច់ទន្លេសម្រាប់នាំចេញ" ដែលមានប្រភពចេញពីប្រទេសកម្ពុជា ហើយជាខ្សាច់ដែលគេយកទៅប្រើក្នុងការសាងសង់ ប៉ុន្តែគេមិនបានបញ្ចេញឈ្មោះអ្នកនាំចេញឡើយ ។

លោក ហ៊ុន សែន បានហាមមិនឱ្យមានការនាំចេញខ្សាច់ដែលបូមចេញពីទន្លេកាលពីឆ្នាំ២០០៩ ក្នុងគោលបំណងការពារជីវចម្រុះក្នុងទឹក ។

លោក អ៊ិត ប្រាំង រដ្ឋលេខាធិការក្រសួងរ៉ែ និងថាមពលបានបញ្ជាក់ថា ការបូមខ្សាច់ចេញពីទន្លេដើម្បីនាំចេញ គឺនៅតែខុសច្បាប់ ប៉ុន្តែលោកបានលើកឡើងថា ក្រុមហ៊ុនមួយចំនួនត្រូវបានអនុញ្ញាតឱ្យនាំចេញខ្សាច់ដែលបូមចេញពីព្រែកប្រសិនបើមានអាជ្ញាប័ណ្ណ ។

កាលពីខែវិច្ឆិកា ឆ្នាំ២០១៣ ប្រព័ន្ធផ្សព្វផ្សាយឥណ្ឌាមួយបានចុះផ្សាយថា ខ្សាច់ទន្លេកម្ពុជាប្រមាណ៣២.០០០តោន ដែលគិតជាទឹកប្រាក់ប្រហែល១,៥លានដុល្លារ ត្រូវគេយចាប់ឃាត់ទុកនៅកំពង់ផែ Cochin អស់រយៈពេលជាង៦ខែ ។

យោងតា មមន្ត្រីកំពង់ផែនេះបានឱ្យដឹងថា ឥឡូវនេះខ្សាច់ទាំងនេះបានឆ្លងកាត់គយរួចហើយ ប៉ុន្តែក្រុមហ៊ុន Raja Steel Private ដែលជាអ្នកនាំចូលក៏កំពុងជួបការលំបាកក្នុងការស្វែងរកអ្នកទិញដែរ ៕



## តមកទំព័រទី ១៦ តុលាការចោទប្រកាន់បុរសបីនាក់ពី...

ប៉ុន្តែផ្ទុយទៅវិញ ពួកគេបាញ់សម្លាប់គាត់យ៉ាងឃោរឃៅទៅវិញ" ។

លោកបានសន្និដ្ឋានថា ចៅក្រមស៊ើបសួរនឹងចំណាយពេលយ៉ាងតិចក៏បីខែដែរដើម្បីព្យាយាមកំណត់មូលហេតុពិតប្រាកដនៃការបាញ់សម្លាប់នេះ ។

ប៉ុន្តែមានការបារម្ភថា ការចាប់ខ្លួន និងការចោទប្រកាន់ដ៏ឆាប់រហ័សបែបនេះមានន័យថាអាជ្ញាធរកំពុងការពារមន្ត្រីកងរាជអាវុធហត្ថជាន់ខ្ពស់នៅក្នុងស្រុកស្នួលដែលមានពាក្យចចាមអារ៉ាមថា នៅពីក្រោយការរកស៊ីកាប់ឈើខុសច្បាប់នៅក្នុងតំបន់នេះ ។

លោកស្រី ឡូរ៉ា ឃីង (Laura King) អ្នកគ្រប់គ្រងផ្នែកទំនាក់ទំនងនៅមជ្ឈមណ្ឌលកម្ពុជាដើម្បីប្រព័ន្ធផ្សព្វផ្សាយឯករាជ្យបានមានប្រសាសន៍ថា ត្រូវធ្វើការស៊ើបអង្កេតឱ្យបានហ្មត់ចត់ដើម្បីរកឱ្យឃើញមូលហេតុនៃការសម្លាប់នេះ និងដើម្បីធានាថា អ្នកដែលពាក់ព័ន្ធត្រូវយកទៅផ្តន្ទាទោស ។

លោកស្រីបានមានប្រសាសន៍ថា "ប្រសិនបើយើងមានតុលាការឯករាជ្យពិតប្រាកដ យើងអាចទទួលបានយុត្តិធម៌ពិតចំពោះករណីមនុស្សឃាត និងការបំភិតបំភ័យអ្នកកាសែតឯករាជ្យតាំងពីដំបូងម្ល៉េះចាប់តាំងការបោះឆ្នោតតាមបែបលទ្ធិប្រជាធិបតេយ្យកាលពីឆ្នាំ១៩៩៣" ៕

**សារុន**



តមកទំព័រទី ២០

# ជន្លងចំណងកម្ម

បានគិតក៏បានអនុវត្តយ៉ាងពេញទំហឹងដែរ ។ចំណែកឪពុកម្តាយ ខេមរា គាត់ពុំដែលមានកង្វល់អ្វីកើតឡើងដល់រូបគាត់ និងកូននោះទេ ពីព្រោះក្នុងគ្រួសារគាត់ អ្វីៗទាំងអស់គាត់បានទទួលយ៉ាងពេញបរិបូរណ៍ពីផលដំណាំ ដែលបង្កបង្កើតពីចំការស្រែរបស់គាត់មកសម្រាប់ផ្គត់ផ្គង់គ្រួសាររបស់គាត់ដែលមានគ្នាតិច ប៉ុន្តែគាត់មានចំការស្រែច្រើន ។

ដោយសារគ្រួសារនេះ មានជីវភាពល្អ ហើយពុំមានកង្វល់អ្វីក្នុងគ្រួសារ ហើយគាត់គិតថា អ្វីៗទាំងអស់ជារបស់ផងគាត់ ។ គាត់ពុំបានគិតអ្វីក្រៅពីខិតខំធ្វើកិច្ចការ សម្រាប់គ្រួសាររបស់គាត់ ហើយគាត់ក៏ពុំដែលបានគិតធ្វើនូវអ្វីដែលជាអំពើកេងប្រវ័ញ្ច បន្លំយកផ្ទះ និងចំការស្រែរបស់ជន្លងដ៏ស្លូតបូតនេះ ។ដូច្នេះកិច្ចការអ្វីៗដែលគ្រួសារប្តីប្រពន្ធកូនច្រើនធ្វើទាំងប៉ុន្មាន គឺសុទ្ធតែបង្កប់នូវល្បិចកលទាំងអស់ ។

ពេលវេលាបានកន្លងទៅ យ៉ាងឆាប់រហ័ស ស្ថានភាពនៅក្នុងគ្រួសារទាំងពីរ ក៏មានការប្រែប្រួលពីតំណាក់ការមួយ ទៅតំណាក់កាលមួយ ។ គួរឱ្យសោកស្តាយណាស់ ដោយគ្រួសារទាំងពីរបានលាចាកលោកទៅ ដោយគ្រាន់តែទុកបណ្តាំឱ្យកូនប្រុសកូនស្រីរៀងខ្លួន ឱ្យខំប្រឹងធ្វើនូវអ្វីដែលគាត់គិតទុកជាស្រេចពេលមានជីវិតរស់នៅនោះ ។ ម្លោះហើយកូនទាំងពីរគ្រួសារនេះបានចងចាំបណ្តាំឪពុកម្តាយ ក៏ខិតខំយ៉ាងហ្មឹងម៉ាត់ដើម្បីឱ្យបានសម្រេចតាមផែនការដែលឪពុកម្តាយបានផ្តាំ ។

ដោយមានការធ្វេសប្រហែសរបស់ ខេមរា ពុំបានប្រុងប្រយ័ត្នឱ្យបានខ្លាំងក្លា ទើបធ្វើឱ្យបងប្អូនរបស់នាង អែម ចូលមកស្នាក់នៅពេញផ្ទះរបស់ខ្លួន ហើយយកចំការស្រែមកធ្វើយកផលដើម្បីយកខ្លួនឯង និងផ្តល់ផលទៅឱ្យគ្រួសារខាងប្តីតែបន្តិចបន្តួច ។

លុះពេលយូរបន្តិចទៅរបស់របរសំខាន់ៗត្រូវយកមកបែងចែក ទៅឱ្យបងប្អូននាង អែម ហើយទុកជារបស់ផងខ្លួនជារៀងរហូតតទៅ ។ ទោះបីនាយ ខេមរា ដឹងថា ប្រពន្ធរបស់ខ្លួនបានធ្វើដូច្នេះយ៉ាងណាក៏ដោយ ដោយសារការលួងលោមផ្អែមល្ហែម និងពង្វក់ឱ្យជាប់ចិត្ត ដកមិនរួចដោយក្តីស្នេហាលើសម្រស់ដ៏ស្រស់ប្រិមប្រិយរបស់នាង អែម ក៏បណ្តោយឱ្យរបស់អ្វីៗដែលនាង អែម សុំបានធ្លាក់ទៅក្នុងកណ្តាប់ដៃបងប្អូននាង អែម ទាំងអស់ ។



ចំណោរតមកកូនចៅរបស់ ខេមរា និងនាង អែម ត្រូវបានត្រួតត្រា និងគ្រប់គ្រងនូវអ្វីៗទាំងអស់ ហើយប្អូនស្រីរបស់ ខេមរា ក៏ត្រូវរស់នៅជាអ្នកជ្រកកោណជាមួយគេទៅតាមយថាកម្មដែរ ។

នេះហើយជាលទ្ធផលមួយ ដែលចេញមកអំពីជន្លងចំណងកម្មត្រូវឱ្យគ្រួសារនាយ ខេមរា ត្រូវរស់នៅក្នុងអំពើមួយ ដែលគេបានប្រើល្បិចកល យកអស់ទ្រព្យសម្បត្តិរបស់ខ្លួន ហើយខ្លួនឯង ត្រូវរស់នៅដោយជាប់ចំណងកម្មជារៀង រហូតតទៅឥតមានពេលរើបំរម្រះឱ្យរួចបានឡើយហោង ៕ **ចប់**

***និពន្ធដោយ : ម៉ម យឹន ក្រុងហ្វីឡាដែលហ្វីយ៉ា ស.រដ្ឋអាមេរិក***


## មជ្ឈមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល

LOWELL ELDER CARE
978-596-1111

345 Chelmsford St. Lowell, MA 01851/ – www.lowelleldercare.com

### អ្វីទៅជាមណ្ឌលថែទាំមនុស្សចាស់ក្រុងឡូវែល?

គឺជាលំនៅដ៏កក់ក្តៅមួយ ដែលផ្តល់សេវាមានកម្មវិធីជាក់លាក់ដល់សហគមន៍បំណង់ គឺគាំទ្រឲ្យមនុស្សចាស់ជរាអាចរស់នៅដោយឯករាជ្យខ្លួនឯង និងជួយឲ្យមានសុខុមាលភាពផ្នែកផ្លូវកាយ ផ្លូវចិត្ត និងផ្នែកសង្គម ។ កម្មវិធីរបស់យើងធានានូវបរិស្ថានរស់នៅមួយប្រកបដោយសុវត្ថិភាព និងមានបរិយាកាសដូចជាផ្ទះរបស់ពួកគាត់ ។

### ទីតាំងនៃមណ្ឌល

ទីតាំងអាចរកឃើញដោយងាយក្នុងអគារថ្មី ជាមួយនូវការតុបតែងរចនាបែបសិល្បៈខ្មែរយ៉ាងល្អប្រណិត ។ មានបន្ទប់ទទួលទានអាហារស្អាត និងមានពន្លឺគ្រប់គ្រាន់ បន្ទប់អានសៀវភៅ បន្ទប់កុំព្យូទ័រ បន្ទប់សម្រាក បន្ទប់មើលភាពយន្ត និងកន្លែងផ្សេងៗទៀតជាទីពេញចិត្តរបស់លោកអ្នក ។





### មណ្ឌលផ្តល់សេវាដល់មនុស្សចាស់

- មានរថយន្តជូនដំណើរទៅវិញទៅមកពីផ្ទះលោកអ្នក
- ការពិនិត្យ និងថែទាំសុខភាព
- ការព្យាបាលតាមរយៈការហាត់ប្រាណ
- កិច្ចការសង្គម ( ផ្តល់ការពិគ្រោះផ្ទាល់ខ្លួន និងក្រុមគ្រួសារ )
- ម្ហូបខ្មែរក្តៅៗ និងចំណីផ្សេងៗ
- ការហាត់ប្រាណសំរាប់សុខភាពរាងកាយ
- កម្មវិធីសិល្បៈ និងតន្ត្រី
- ការអប់រំពីសុខភាព
- ការពិភាក្សាលើព្រឹត្តិការបច្ចុប្បន្ន (និងការសំណេះសំណាលគ្នា)
- សកម្មភាព និងដំណើរកំសាន្តក្រៅមណ្ឌល

### Our Services

- Door-to-Door Transportation
- Medical Care and Support
- Physical Therapy
- Social Worker
- Khmer Meals and Snacks
- Adaptive Physical Exercise
- Music Programs
- Health Educational Seminars
- Discussions on current events, (and times of reminiscing)
- Outdoor Field Trips

**សូមហៅលេខទូរស័ព្ទ (978) 596-1111**

តមកទំព័រទី ១៧

## គណបក្សសង្គ្រោះជាតិលើកឡើងថា...

ដើម្បីជួយឃោសនាគណបក្សសង្គ្រោះជាតិដែលគេមិនអនុញ្ញាតឱ្យបង្កើតស្ថានីយទូរទស្សន៍អំឡុងយុទ្ធនាការឃោសនាបោះឆ្នោត ។

ប្រជាប្រិយភាពនៅលើបណ្ដាញទំនាក់ទំនងសង្គមរបស់កញ្ញាបានកើនឡើងខ្លាំងយ៉ាងឆាប់រហ័សដោយធ្វើឱ្យនាងក្លាយជាមេដឹកនាំមួយរូបក្នុងចំណោមមេដឹកនាំគណបក្សសង្គ្រោះជាតិ ប៉ុន្តែកាលពីខែកុម្ភៈ គណបក្សសង្គ្រោះជាតិបានចេញសេចក្ដីថ្លែងការណ៍មួយដោយបណ្ដេញកញ្ញាចេញពីគណបក្ស ។ សកម្មជននានារបស់គណបក្សសង្គ្រោះជាតិបានចោទប្រកាន់នៅពេលនោះថា កញ្ញា សុវណ្ណថា កំពុងតែធ្វើការជាមួយគណបក្សប្រជាជនកម្ពុជាដើម្បីបំបែកសំឡេងគណបក្សប្រឆាំង ។

ការចោទប្រកាន់នោះត្រូវបានធ្វើឱ្យលេចឡើងជាថ្មីម្ដងទៀតកាលពីថ្ងៃសុក្រ ដោយកញ្ញា កឹម មនោវិទ្យា ជាកូនស្រីរបស់លោក កឹម សុខា និងជាអនុប្រធានផ្នែកកិច្ចការសាធារណៈរបស់គណបក្សសង្គ្រោះដែលបានសរសេរនៅលើទំព័រហ្វេសប៊ុករបស់នាងដោយអះអាងថា លោក កែម ឡី អ្នក វិភាគនយោបាយ និងកញ្ញា សុវណ្ណថា មានផែនការបង្កើតគណបក្សថ្មីមួយ ។

កញ្ញា មនោវិទ្យា បានសរសេរថា "គណបក្សថ្មីមួយនឹងត្រូវបង្កើតឡើង ប៉ុន្តែឥឡូវនេះពួកគេបង្កើតសម្ព័ន្ធមួយដើម្បីតាមដានកំណែទម្រង់ និងសម្ព័ន្ធយុវជនផ្សេងៗទៀតជាបណ្ដោះអាសន្ន ដើម្បីកុំឱ្យសាធារណជនរិះគន់ថា ពួកគេកំពុងបំបែកសំឡេងរបស់យើង" ។

កញ្ញា មនោវិទ្យា បានសរសេរបន្តថា "នៅពេលការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់មកដល់ក្រុមទាំងនេះនឹងបង្កើតគណបក្សមួយដោយយកលេសថា គណបក្សសង្គ្រោះជាតិមិនបានទទួលជោគជ័យនៅក្នុងការធ្វើឱ្យមានកំណែទម្រង់ ។ នេះជាសិទ្ធិនយោបាយរបស់ពួកគេ ។ វាគ្រាន់តែជាការធ្វើឡើងមួយដែលគ្មានប្រយោជន៍ ហើយនឹងធ្វើឱ្យប៉ះពាល់ដល់ការសាមគ្គីគ្នាក្នុងចំណោមអ្នកប្រជាធិបតេយ្យតែប៉ុណ្ណោះ" ។

ចាប់តាំងពីច្របាច់បញ្ចូលគ្នារវាងគណបក្សសិទ្ធិមនុស្ស និងគណបក្ស សម រង្ស៊ី ដើម្បីបង្កើតគណបក្សថ្មីមួយគឺគណបក្សសង្គ្រោះជាតិកាលពីខែកក្កដា ឆ្នាំ២០១២មក លោក កឹម សុខា និងលោក សម រង្ស៊ី ដែលជាមេដឹកនាំគណបក្សប្រឆាំងបានផ្ដោតយ៉ាងខ្លាំងលើការរួបរួមគ្នា ហើយលើកឡើងថា ការប្រកួតប្រជែងគ្នាពីមុនរបស់គណបក្សទាំងពីរនេះមិនមានអ្វីប៉ះពាល់ដល់ការសាមគ្គីគ្នាដើម្បីប្រឆាំងនឹងគណបក្សប្រជាជនកម្ពុជាឡើយ ។

ការបោះឆ្នោតជ្រើសរើសសមាជិកក្រុមប្រឹក្សាឃុំ-សង្កាត់គ្រោងធ្វើឡើងនៅខែកុម្ភៈ ឆ្នាំ២០១៧ នឹងជាការបោះឆ្នោតដ៏ធំលើកដំបូងសម្រាប់គណបក្សសង្គ្រោះជាតិចាប់តាំងពីគណបក្សនេះទទួលបានអាសនៈចំនួន៥៥នៅក្នុងរដ្ឋសភាដែលមានអាសនៈសរុបចំនួន១២៣ រីឯគណបក្សប្រជាជនកម្ពុជាទទួលបាន៦៨អាសនៈអំឡុងការបោះឆ្នោតជាតិកាលពីឆ្នាំមុននោះ ។

កញ្ញា មនោវិទ្យា បានលើកឡើងថា ការបង្កើតក្រុមទាំងនោះនឹងជាជំហានដំបូងនៃគម្រោងដ៏ធំមួយដើម្បីបង្កើតគណបក្សថ្មីមួយមកប្រកួតប្រជែងនឹងគណបក្សសង្គ្រោះជាតិ ។

កញ្ញាបានសរសេរបន្តនៅលើទំព័រហ្វេសប៊ុករបស់នាងថា "វាគឺជាការប៉ុនប៉ងមួយ ដើម្បីទាញយកប្រជាប្រិយភាពក្នុងពេលបច្ចុប្បន្នរបស់គណបក្សសង្គ្រោះជាតិដែលទទួលបានការគាំទ្រពីក្រុមយុវជនផ្សេងៗ ដោយពុំចាំបាច់បង្កើតអ្វីៗដោយខ្លួនឯង ។ វាច្បាស់ណាស់ថា គ្មានក្រុមណាអាចកៀងគរការគាំទ្រពីសំណាក់ប្រជាពលរដ្ឋយ៉ាងច្រើនបានឡើយដោយគ្មានយកឈ្មោះគណបក្សសង្គ្រោះជាតិទៅប្រើនោះ" ។

កញ្ញា មនោវិទ្យា បាននិយាយតាមទូរស័ព្ទកាលពីម្សិលមិញថា លោក កែម ឡី គឺជាអ្នកដឹកនាំផែនការសម្រាប់បង្កើតគណបក្សថ្មី ហើយថា កញ្ញា សុវណ្ណថា គឺជាមនុស្សដែលត្រូវបានគេប្រើប្រាស់ដើម្បីសម្រេចមហិច្ឆតានយោបាយរបស់លោក កែម ឡី ។

កញ្ញាបាននិយាយថា "ស្ត្រីណាក៏អាចមានផែនការរបស់ខ្លួនដែរ ។ វាគឺជាក្រុមរបស់លោក កែម ឡី ។ លោកកំពុងតែព្យាយាមទាញយកការគាំទ្រពីយុវជន ហើយលោកឃើញអ្នកដែលមានប្រជាប្រិយភាពនៅលើទំព័រហ្វេសប៊ុក ហើយចង់ទាញយកពួកគេមកបម្រើមហិច្ឆតារបស់ខ្លួន" ។

ចាប់តាំងពីការបោះឆ្នោតជាតិកាលពីខែកក្កដា ឆ្នាំ២០១៣មក លោក កែម ឡី បានអភិវឌ្ឍកេរ្តិ៍ឈ្មោះជាអ្នកវិភាគនយោបាយរបស់ខ្លួនយ៉ាងខ្លាំង ដោយជារឿយៗតែងតែបង្ហាញខ្លួនក្នុងកម្មវិធីវិទ្យុជាភាសាខ្មែរមួយចំនួន ដូចជាវេទិកាអ្នកស្ដាប់វិទ្យុអាស៊ីសេរីជាដើម ។

